# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ១១ វិច្ឆិកា

ព.ស. ២៥០២ គ.ស. ១៩៥៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* — **បញ្ជីរឿង** — *ទំព័រ*

- ពុទ្ធនិយមនឹងជាតិនិយម លោករដ្ឋលេខាធិការ សូ- ណែម រៀបរៀង . ១២០៥
- កាយសន្តិការកថា របស់ព្រះវិន័យធម្ម ជោង-យុ . . . ១២១១
- សុរពជាតក (តបប់) លោក ចង-វង ចម្លងពីសាស្ត្រាស្លឹករឹត . . ១២២៥

*ផ្នែកអក្សរសាស្ត្រ*

- រឿងហង្សយន្ត (តមក) លោក អឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត . . ១២៣៩
- គតិបណ្ឌិតរបស់ព្រះបាទ ម៉ាក់-អូរ៉ែល ព្រះអធិរាជរ៉ូម៉ាំង
  លោក ភ៊ឹយ-ប៊ុក ដកស្រង់រៀបរៀង . . . . ១២៥៧
- រឿងព្រេងនឹងរឿងបុរាណប្រទេសជប៉ុន (តមក) លោក ភ៊ឹយ-ប៊ុក រៀបរៀង . ១២៦០
- រឿងស្រីគ្រប់ល័ក្ខណ៍ (តមក) យុក-វដីរ រៀបរៀង លោក ដេង-ជ្រីវ ពិនិត្យ . ១២៧៦
- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . ១២៩៤
- បិសាចនឹងចចក លោក ដេង-ជ្រីវ រៀបរៀង . . . . ១៣០១
- រឿងសាមកុក (តមក) ឧកញ៉ា ឡុ-កន ប្រែ . . . . . . ១៣០៨

*ផ្នែកកំណត់ទីនីប្រវត្តិការណ៍*

- ពតិមានផ្សេង ៗ របស់ក្រសួងធម្មការ . . . . . . ១៣១៨
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . ១៣២០

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃផ្សារ ២៣០រ០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :


— Le Bouddhisme et le Nationalisme par M. SO-NÈM . . . 1205
— Kayasantibhàvakathà par PREAH VINAYADHAMMA THONG-YOU . . . . . . . . . . . . . 1211
— Surabajataka (suite et fin) relevé du manuscrit sur feuilles de latanier par M. THANG-VONG . . . . . 1225


### Partie littéraire :


— Histoire de Hang-Yon (suite) relevée du manuscrit sur feuilles de latanier par M. IM-PHON . . . . . . . . 1239
— Les Pensées de Marc Aurèle Empereur Romain, traduites par M. RAY BUC . . . . . . . . . . . . . 1257
— Contes et Légendes du Japon (suite) traduits par M. RAY-BUC. 1260
— La femme vertueuse par Yok Vochir revue et corrigée par M. PHENG-CHRIV . . . . . . . . . . 1276
— Légende de Marana Mâtâ (suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . . . 1294
— Le démon et le loup par M. PHENG-CHRIV . . . . 1301
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1308


### Notes et Chroniques :


— Nouvelles diverses du Ministère des Cultes . . . . . . . 1318
— Dictionnaire Sanskrit-khmer (suite) par Preah Maha PANG-KHAT . . . . . . . . . . . . . 1320


---


Prix d'abonnement annuel (comprenant 12 numéros): 230$00.

## ផ្នែកសាសនា

# ពុទ្ធនិយមនិងជាតិនិយម

លោក ស៊ូ-ណែម រដ្ឋលេខាធិការក្រសួងធម្មការ រៀបរៀង

---

ការធ្វើអត្ថាធិប្បាយពីព្រះពុទ្ធសាសនា ឬ ហៅម្យ៉ាងទៀតថា ព្រះពុទ្ធនិយម ជាការទូលំទូលាយពន់ពេក នឹងរកប្រៀបធៀបពុំបាន ។ ព្រះពុទ្ធនិយមនេះ បានជ្រួតជ្រាប បែកសាខា បែកផ្កាយគ្រប់ទិសានុទិស ចេញជាគំនិត ដែលបានចងក្រងជាសាស្ត្រា ជាសៀវភៅ ជាអត្ថបទច្រើនមិនឥតគណនាបាន ទៅតាមសញ្ជាតិនិងតាមភាសាទៃៗ ។

ក្នុងទំព័រជាក់នៃ "ទស្សនាវដ្ដី" នេះ បំណងធំបំផុត គឺប្រាថ្នាត្រឹមតែវែកញែកជូនអ្នកអានទាំងឡាយជ្រាបថា គោលការនៃពុទ្ធនិយម និងគោលការនៃជាតិនិយមមានលំនាំស្របគ្នា ឬ ក៏ផ្ទុយគ្នាយ៉ាងណា? ។

ពុទ្ធនិយម ជាទស្សនវិជ្ជាមួយ ក្នុងចំណោមទស្សនវិជ្ជាជាច្រើន ដែលបានចាប់បដិសន្ធិក្នុងលោក ។ ទស្សនវិជ្ជានេះ ដូចអស់លោកអ្នកជ្រាបស្រាប់ ជាលទ្ធផលនៃការរៀន ការស្រាវជ្រាវ ការរិះគិត ការពិចារណា ចំពោះការដោះស្រាយនូវបញ្ហាទូទៅនៃពិភពលោក ជាពិសេសចំពោះបញ្ហាសង្គម របស់អ្នកប្រាជ្ញម្នាក់ ព្រះទស្សនវិទូមួយ

ព្រះអង្គ ដែលពុំមែនអ្នកណាក្រៅពីព្រះសមណគោតម ព្រះសម្មាសម្ពុទ្ធនេះឯង ។ ដូច្នេះព្រះពុទ្ធនិយម មិនមែនជាអ្វីក្រៅពីមនុស្សនិយម គោលគឺការដោះស្រាយបញ្ហាមនុស្ស មិនមែនដូចសាសនានានាដទៃទៀត ដែលជាប់ទៅគន់សភាពនៃសាសនាពិត។ ដោយស្ថិតនៅលើជំនឿតែមួយមុខ គ្មានការពិចារណា ជំនឿទៅលើវត្ថុលើកម្លាំងវិសាមញ្ញផ្សេងៗ មានគាទិទេពជាដើម ។

ឯមូលដ្ឋានដ៏មុតមាំនៃពុទ្ធនិយមនេះ ស្ថិតនៅលើព្រះធម៌ ទីងលើអស់ជនានុជន ដែលគោរពនឹងប្រតិបត្តិតាមព្រះធម៌នេះ ។ ការគោរពតាមព្រះធម៌ព្រះពុទ្ធ បើពោលម្យ៉ាងទៀតថា ការស្វែងរកព្រះធម៌ គឺមិនសំដៅយកវត្ថុអ្វី ក្រៅពីការគោរពប្រតិបត្តិតាមមាគ៌ា ដែលព្រះសម្មាសម្ពុទ្ធបានទ្រង់ត្រាយទុកមក ក្រៅពីការស្វែងរកផ្លូវ ដើម្បីឲ្យទៅដល់ទីសុភមង្គលគឺព្រះនិព្វាន ។

ចុះគោលការនៃជាតិនិយម មានលំនាំយ៉ាងណាទៅ?

បើប្រៀបធៀបទៅនឹងពុទ្ធនិយម យើងអាចទុកជាតិនិយមជាលទ្ធិមួយ ជាទស្សនវិជ្ជាមួយបាន ដូចទស្សនវិជ្ជានានាដែរ ។ ព្រោះជាតិនិយមក៏ស្ថិតនៅលើគំនិត ដែលមានន័យវែងឆ្ងាយ មានការមិនធ្វើអ្វីដែលអាចនាំមកនូវសេចក្តីសៅហ្មង - សេចក្តីវិនាសដល់ជាតិ - ការមិន

ចំរើនប្រយោជន៍ជាតិដទៃ ហើយប្រតិបត្តិតែសកម្មភាពណាដែលហុចនូវសេចក្ដីសុខ សេចក្ដីចំរើនដល់ជាតិ ។ បើនិយាយយ៉ាងខ្លី ជាតិនិយមជាផ្លូវដើម្បីឈានយកនូវសុភមង្គលជូនជាតិ ក្រោមការដឹកនាំដ៏មុះមុតនៃរដ្ឋបុរស ឬវីរបុរសណាម្នាក់ ។

ចំពោះខ្មែរយើង ជាតិនិយមបានកាន់យកជាស្រេចនូវមាគ៌ាដ៏ប្រពៃមួយ មាគ៌ាដែលសម្ដេចព្រះឧបយុវរាជទ្រង់បានរកឃើញជូនជនរួមជាតិ ក្នុងព្រះសុន្ទរកថា ព្រះសង្កថា នឹងទ្រង់សព្វព្រះរាជហឫទ័យ ចង្អុលជាច្បាស់លាស់ថ្មីទៀត ក្នុងអត្ថបទនានារបស់ព្រះអង្គ ក្នុងទំព័រសារពត៌មាន "អ្នកជាតិនិយម" ដែលបង្អួចបានគានរួចហើយក្ដី ហើយដែលបង្អួចនឹងបានក្រោយនេះជាលេខ ៗ ទៅក្ដី ។

សេចក្ដីដែលបានពណ៌នាមកដោយត្រួស ៗ នេះ គំសឹងចង្អុលជូនអស់លោកអ្នកជ្រាបខ្លះហើយថា ពុទ្ធនិយមនឹងជាតិនិយមមិនមែនជាលទ្ធិជាទស្សនវិជ្ជាផ្ទុយគ្នាទេ ។

នៅកម្ពុជាយើង ប្រវត្តិសាស្ត្របានទុកភស្តុតាងដ៏ជាក់លាក់ ចំពោះដំណើរស្របគ្នានេះ ចំពោះការពាក់ព័ន្ធសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងដំណើរទាំងពីរ ។ ជាពិសេសយើងបានដឹងច្បាស់ថា ព្រះពុទ្ធ-សាសនា ជាអង្គការទ្រទ្រង់ជាតិនិយមខ្មែរជាយូរអង្វែងរហូតមកដល់សព្វ

ថៃ ។ ការផ្សាយខ្មែរយើងមានវប្បធម៌ជាដើម ដែលមានកិត្តិសព្ទល្បីល្បាញ តែងបានទទួលឧបត្ថម្ភពីព្រះពុទ្ធសាសនាដរាបមក ។ ជាឧទាហរណ៍ យុវជនយើងជាន់ដើម តែងចូលទៅស្រង់យកចំណេះវិជ្ជា ទៅទទួលសេចក្ដីអប់រំពីវត្តអារាម ពីព្រះសង្ឃាចារ្យ ។ កាលបើបានបួសរៀនអប់រំកិរិយាមារយាទគ្រប់គ្រាន់ហើយ ។ បើបានលាសិក្ខាបទមកកាន់ភាពជាគ្រហស្ថវិញ (បណ្ឌិត) ទើបជនរួមជាតិទទួលរាប់អានថាជាជនត្រឹមត្រូវ ជាជនល្អដោយគុណធម៌ ទើបអាចរកគូកិរិយាបានសមរម្យ ហើយប្រកបរបររកទទួលទានត្រឹមត្រូវតាមសម្មាអាជីវៈតទៅ ។

អ្នកខ្លះពោលថា កម្ពុជរដ្ឋយើង កាលដើម គេបានស្គាល់នូវសេចក្ដីរុងរឿងខ្លាំងណាស់ ជនជាតិខ្មែរដែលមានព្រះមហាក្សត្រជាប្រមុខ សុទ្ធសឹងជាអ្នកអង់អាចក្លាហាន មានសកម្មប្រយុទ្ធដ៏មុតមាំ ដើម្បីការពារកេរប្រយោជន៍ កិត្តិសព្ទកិត្តិនាមជូនជាតិមាតុប្រទេស ។

ហើយថា ក្រោយដែលបច្ចាមិត្តបាននាំព្រះពុទ្ធសាសនានេះ មកទុកជាកេរ្តិ៍មតិក លក្ខណៈដ៏វិសេសនេះ ក៏អន់ថយសាបសូន្យទៅ នាំប្រទេសចូលទៅក្នុងហិនភាពជាយូរឆ្នាំរៀងដរាបមក ទល់នឹងរជ្ជកាលព្រះនរោត្តម សីហនុវរ្ម័ននេះ ។ ព្រោះព្រះពុទ្ធសាសនាប្រដៅនូវការលាចាកសម្បត្តិលោក នូវការលះបង់កិលេសតណ្ហា លោភៈ ដើម្បីយក

បរលោកដ៏ក្ដីស្ងាន ។

កាលបើបានពិនិត្យដោយម៉ត់ចត់ទៅ អ្នកនឹងយល់ឃើញថា ការតិះដៀលនេះ មិនប្រកបដោយពាក្យសត្យឡើយ ។ ព្រោះសាវតារបានចង្អុលច្បាស់ អំពីបុព្វហេតុដែលនាំឲ្យកម្ពុជរដ្ឋយើងទទួលនូវសេចក្ដីអប្បយសមុននេះ ។ ការបែកបាក់សាមគ្គីរវាងខ្មែរនឹងខ្មែរមកពីលោភៈ មកពីការយល់ប្រយោជន៍ផ្ទាល់ខ្លួន មកពីខ្មែរយើងបានលះបង់នូវជាតិនិយមទៅបំរើប្រយោជន៍នៃបរទេស ។ គឺហេតុទាំងអស់នេះហើយ ដែលនាំឲ្យដែនដីខ្មែរយើងរួមមកនៅតូចត្រឹមទំហំសព្វថ្ងៃ ។

រីឯព្រះពុទ្ធោវាទវិញ ក៏មិនជួយនាំប្រយោជន៍ប្រទេសឡើយ ព្រោះល្គឹកណា មិនទាន់រកឃើញនូវលោកុត្តរធម៌ មិនទាន់បានជួបប្រទះនូវព្រះនិព្វាននៅឡើយទេ ល្គឹកនោះ លោកគតិនឹងធម្មគតិក៏រមែងអន្ទោលចូលគ្នាទៅវិញទៅមកជាដរាប ។

ក្នុងបច្ចុប្បន្នកាលនេះ លើកលែងតែជនខ្លះ ខេមរជនទូទៅសឹងបានកាន់យកនូវទីបធម៌ ៤ ប្រការ ស្របទាំងគតិលោក ទាំងគតិធម៌ ដើម្បីស្វែងរកសេចក្ដីសុខ សេចក្ដីចំរើនជូនជាតិមាតុប្រទេស ។ ទីបធម៌ទាំង ៤ ប្រការនេះមាន :

១– ឧដ្ឋានៈ ការម្នីម្នាប្រកបការងារដែលត្រូវប្រកប;

២– អប្បមាទៈ ការមិនភ្លេចស្មារតី;

៣- សញ្ញាមៈ ការប្រយ័ត្នឥន្ទ្រិយទាំង ៦;

៤- ឧមៈ ការទូន្មានចិត្តឲ្យមានបែបបទល្អ ៗ

ការប្រកបការងារ ដែលត្រូវប្រកបនេះហើយ ដែលជាបញ្ហាធំសព្វថ្ងៃនៅប្រទេសយើង ៗ កាលបើទដ្ឋានៈនេះ មានដំណើរស្រួលបួល បញ្ហាធំគឺ ឯករាជ្យខាងសេដ្ឋកិច្ច នឹងបានសម្រេចដូចព្រះរាជបំណង នៃសម្ដេចព្រះឧបយុវរាជជាមិនខាន ៗ ការបរិបូណ៌នូវផលិតផល ដែលប្រជាពលរដ្ឋយើងខំប្រឹងប្រែងធ្វើ នឹងនាំមកនូវសេចក្ដីសប្បាយរីករាយក្នុងសង្គមជាតិ ៗ ឯករាជ្យ នឹងសម្បូរណភាព នឹងរឹងរឹតតែរឹងប៉ឹងពេញលេញរៀងរាបដរាបទៅ ៗ

---

# កាយសន្តិភាវកថា

របស់ព្រះវិន័យធម្ម ថោង-យុ វត្តសាកវ័នតេជោ

---

## ធមោ ៣ ជឹង

សូមនមស្ការ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌ មួយអន្លើដោយពពួកនៃព្រះអរិយសង្ឃសាវ័ក (ដោយសេចក្តីគោរព) ។

សូមពណ៌នាពាក្យថា កាយសន្តិភាព ដែលមានក្នុងអដ្ឋកថាធម្មបទដូចតទៅ ៖

ពាក្យថា កាយសន្តិភាព នេះ មកអំពី កាយ ប្រែថា " រូបដែលជាទីប្រជុំអាការៈ៣២ មានសក់, រោម, ក្រចកជាដើម រួមទាំងអស់ហៅថា កាយ " នឹង សន្តិ ប្រែថា " ស្ងប់, សាន្តត្រាណ, រាបទាប, សះជាទីនឹង " នឹង ភាវ ប្រែថា " ភាព ឬដំណើរ " រួមពាក្យនេះចូលគ្នាជា កាយសន្តិភាព ប្រែថា " ភាព ឬដំណើរស្ងប់, សាន្តត្រាណ, រាបទាប, សះជាទីនឹងខាងផ្លូវកាយ " ។

សូមលើកយកអត្ថបទនេះ មកពណ៌នាបំភ្លឺដើម្បីបញ្ជាក់ត្រង់ពាក្យថា " ស្ងប់កាយ " នោះ ដូចតទៅ ៖

កាយសន្តិភាព ភាព ឬដំណើរស្ងប់ខាងផ្លូវកាយ ។

**អធិប្បាយ** ហេតុ ឬឧបាយដែលនាំឲ្យស្ងប់ខាងផ្លូវកាយ បាន ខានការប្រព្រឹត្តវៀរចាកមិច្ឆាជីវៈ " ការចិញ្ចឹមជីវិតខុស " របស់គ្រហស

គឺវៀរចាកជំនួញដែលមិនគួរជួញ មានជួញគ្រឿងសស្ត្រាវុធ ( បានដល់គ្រឿងសស្ត្រាផ្គាល់ដែលមានដាវជាដើម, អាវុធគ្រឿងប្រហារមានកាំភ្លើងជាដើម ) ជួញសត្វគឺជួញមនុស្ស, ជួញសត្វ; ជួញទឹកស្រវឹងគឺសុរានិងមេរ័យ, ជួញថ្នាំពិសគឺថ្នាំសម្រាប់បំពុលៈ ។

ចំណែកខាងបព្វជិតពុទ្ធសាសនិកវិញ បានខាងការវៀរចាកអនេសនកម្ម គឺអំពើស្វែងរកមិនគួរ ២១ មានវេជ្ជកម្ម « ធ្វើពេទ្យហ្ម » និងទូតកម្ម « ធ្វើទូត នាំសាសន៍ឲ្យគ្រហស្ថខុសចាកធម្មវិន័យ » ជាដើម ហើយនិងបាបធម៌ គឺធម៌ដ៏លាមក ៥ មានកុហនា « ការកុហក » ជាដើម ហៅថា មិច្ឆាជីវៈ « ការចិញ្ចឹមជីវិតខុស » ។

ការវៀរចាក ការចិញ្ចឹមជីវិតខុសនេះឯង ជាហេតុនាំឲ្យកើតសេចក្តីស្ងប់កាយ ហៅថា កាយសន្តិភាព «ដំណើរស្ងប់ខាងផ្លូវកាយ» ជាហេតុឲ្យបានសេចក្តីសុខជាផល ហៅថា សុខកាយ ព្រោះកាយស្ងប់ឈប់លែងប្រព្រឹត្តបៀតបៀនលោកជិះជាន់ កាប់សម្លាប់ចំពោះមនុស្សសត្វសន្តានជាទីស្រឡាញ់ ។ កាយសន្តិភាព «ដំណើរស្ងប់ខាងផ្លូវកាយ» នេះ សមដូចពុទ្ធភាសិតថា: អព្យាបជ្ឈំ សុខំ លោកេ « ការមិនបៀតបៀនគេ ( គឺមនុស្សជាតិដូចគ្នា ឬ សត្វដែលមានសរីរៈធំ-តូចជាដើម ) ទើបជាសុខក្នុងលោក ត្រង់កាយមិនប្រព្រឹត្តទុច្ចរិត ដោយកាយទ្វារ គឺវៀរចាកការសម្លាប់សត្វ, ការលួចប្លន់ទ្រព្យ

សម្បត្តិរបស់អ្នកដទៃ, ការប្រព្រឹត្តិក្បត់ចិត្តនឹងប្រពន្ធកូនគេ, ការប្រព្រឹត្តិកុងអបាយមុខ "ប្រធាននៃសេចក្តីវិនាស" ៦ យ៉ាងគឺ ក្រេបផឹកទឹកស្រវឹង គឺសុកទឹងមេរ៍យ ដែលជាហេតុនាំឲ្យវិនាសហិនហោចខាតទ្រព្យសម្បត្តិឃើញទាន់ភ្នែកផង, នាំឲ្យចំរើនខាងការឈ្លោះប្រកែកគ្នាផង, ជាហេតុនាំឲ្យកើតរោគច្រើនយ៉ាងផង ជាហេតុនាំបណ្តាលឲ្យខូចកេរ្តិ៍ឈ្មោះឬឲ្យកើតក្តីគរហាទិន្នាផង នាំឲ្យលេចចេញកេរ្តិ៍អាសផង. ជាហេតុធ្វើប្រាជ្ញាឲ្យមានកំឡាំងថយ ឬនាំឲ្យខ្សោយសតិប្រាជ្ញាផង ។ ប្រព្រឹត្តដើរលេងតាមច្រកល្ហកក្នុងវេលាយប់ ដែលជាហេតុនាំឲ្យគេមន្ទិលសង្ស័យចោទប្រកាន់ថាជាចោរ ។ ប្រព្រឹត្តដើរមើលល្បែងមហោស្រព ដែលជាហេតុនាំឲ្យខូចចិត្តនឹងបង់ខាតប្រាក់កាសទ្រព្យធនដែលរកបានមក ។ ប្រព្រឹត្តលេងល្បែងភ្នាល់ ដែលជាហេតុនាំឲ្យលោយទ្រព្យសម្បត្តិ និងក្តៅក្រហាយអន្ទះអន្ទែងក្នុងចិត្ត ។ ប្រព្រឹត្តសេពគប់នឹងបាបមិត្រ ដែលជាហេតុនាំឲ្យប្រព្រឹត្តកាប់សម្លាប់លួចប្លន់ដល់ជីវិតៈគនឹងទ្រព្យសម្បត្តិរបស់គេ ឬជាហេតុនាំឲ្យជាប់គុកច្រវាក់ខ្នោះឃ្នាង វិលច្រអូសនឹងកិច្ចការទាំងពួង ដែលជាហេតុនាំឲ្យខូតខ្សោយ ក្រទ្រព្យសម្បត្តិ និងខាតខូចប្រយោជន៍តម្រិះវិជ្ជាប្រាជ្ញា ។ មួយទៀតការប្រព្រឹត្តផឹកសុក ជក់កញ្ឆា អាភៀន ដែលជាហេតុនាំឲ្យញៀនស្អាំងស្អុមខ្លួន យូរទៅ បង្កកើតទៅជារោគរបេងរីងរៃ ។ ការវៀរចាកអបាយមុខនេះ ឈ្មោះថា ដំណើរនាំឲ្យស្ងប់ខាងផ្លូវ

កាយ ៗ អ្នកដែលមិនបានវៀរចាកវិញនោះ ទឹងសឹមដូចជាសុរា-សិតមួយថា ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងដួង, ពុទ្ធភាសិតក្នុងបរាភវសូត្រថា: ឥត្ថីធុត្ត អ្នកលេងស្រី (មានពួកស្រីផ្កាមាសជាដើម នេះសុទ្ធតែនាំឲ្យកើតរោគក្នុងកាយ), សុរាធុត្ត អ្នកលេងផឹកសុរា សូម្បីសុរាទេភ្ជាយគី ប៉ុយែរ ក៏ពប់បញ្ចូលក្នុងពួកសុរាទាំងមេរ័យទាំងអស់ សុទ្ធតែគ្រឿងស្រវឹង ធ្វើមនុស្សឲ្យវង្វេងវង្វាន់ មានតែនាំឲ្យរឹងរឹតតែកើតបមាទធម៌ពេញទីក្នុងពេលនោះ អក្ខធុត្ត អ្នកលេងល្បែងភ្នាល់ (គឺចាប់តាំងពីបៀរ ប៉ោជាដើមឡើងទៅហៅថា ល្បែងភ្នាល់) ល្បែងភ្នាល់នេះ បើយើងឈ្នះគេថ្ងៃនេះឬថ្ងៃស្អែក កាយទឹងចិត្តក៏នៅតែមិនស្ងប់ មិនស្កប់ស្កល់ដែរ តែបើសិនជាណោចាញ់គេវិញ ដើរ ឈរ អង្គុយ ដេកមិនស្រណុក បក់មិនល្ហើយឡើយ បេះតែមានកិលេស សេចក្ដីសៅហ្មងកករល្អក់ នឹងតណ្ហា សេចក្ដីប្រាថ្នាឬចំណង់មិនចេះអស់.ហើយក្នុងចិត្ត ឆេះរាលដាលដោយភ្លើងគឺលោភៈ "សេចក្ដីចង់បានពេក" ទោសៈ សេចក្ដីប្រទូស្តឬខឹងស្អប់, មោហៈ "សេចក្ដីវង្វេងមិនដឹងសេចក្ដីពិត" ដុតកំដៅឡើង ៗ ឥតស្រាកស្រាន្ត ៗ អ្នកលេងល្បែងភ្នាល់ស៊ីសងនេះ មិនដែលឃើញអ្នកណាមួយមានកំណើតទេ, មានតែលង់លិចខ្លួនទៅជាដរាប ៗ

និទស្សន៍ក្នុងពាក្យថា: កាយសន្តិភាព ដំណើរស្ងប់ខាងផ្លូវ

កាយ ផ្នែកខាងកាយកម្ម តែម្យ៉ាងទេ, តែគង់មានចូលជាប់ទាក់ទង ខាងវចីកម្មនិងមនោកម្មដែរ ។

ដូច្នេះសប្បុរសទាំងឡាយ គប្បីជ្រាបថា: កម្មទាំងបីនេះ សុទ្ធតែចាត់ជាជាតួបាបទាំងអស់ ។ កងបាលីមានសំដែងអំពីបាប ៣ ពួកនេះ ច្រើនជាងចំណែកដទៃៗ ព្រោះបាបអម្បាលនេះ ជាប្រធាននៃបាបទាំងពួង, បាបទាំងនេះ ជួនកាលលោកហៅថា បាប ដែលប្រែថា: កម្មដ៏លាមក, ហៅថា ទុច្ចរិត ប្រែថា: សេចក្ដីប្រព្រឹត្តអាក្រក់, ហៅថា អកុសល ប្រែថា ការមិនល្អ, ហៅថា: អករណីយកិច្ច ប្រែថា កិច្ចមិនគួរធ្វើ, ហៅថា អធម្មចរិយ: វិសមចរិយ: ប្រែថា សេចក្ដីប្រព្រឹត្តមិនជាធម៌, សេចក្ដីប្រព្រឹត្តមិនសម ។

បណ្ដាបាបទាំងប៉ុន្មាន ដែលបានពណ៌នាមកនេះ, ឥតមានចំណែកណាមួយដែលជារបស់គួរធ្វើសោះឡើយ សុទ្ធតែជាកិច្ចមិនគួរធ្វើទាំងអស់ ។

សម្ដេចព្រះភគវន្ដមុនីបរមគ្រូ ទ្រង់ត្រាស់នឹងព្រះអានន្ទត្ថេរថា: ឯកំសេនាហំ អានន្ទ អករណីយំ វទាមិ ប្រែថា ម្នាលអានន្ទ! តថាគត ហៅ កាយទុច្ចរិត វចីទុច្ចរិត និង មនោទុច្ចរិត ថាជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយដាច់ខាត ។

កាលបើបុគ្គលណាមួយជ្រុលកាយ វាចា ចិត្ត ធ្វើអករណីយកិច្ច ត្រូវដឹង ខ្លួនចុះថា មុខជានឹងមានទោស យ៉ាងតិចត្រឹម ៥ យ៉ាងគឺ: ខ្លួនឯងតិះដៀលខ្លួនឯងបាន ១, លោកអ្នកប្រាជ្ញរិះគន់ រមែងតិះដៀលបាន ១, កេរ្តិ៍ឈ្មោះអាក្រក់ រមែងខ្ចរខ្ចាយឡើង ១, វង្វេងវល់ស្មារតីក្នុងវេលាជិតស្លាប់ ១, ខាងមុខអំពីទំលាយខន្ធទៅ រមែងទៅកើតក្នុងទុគ្គតិ ១ ។ កាលបើដូច្នេះ គួរអស់លោកអ្នកទាំងឡាយ អ្នកមានបញ្ញាចក្ខុត្រូវលះបង់អំពើអាក្រក់ដោយកាយឲ្យជ្រះស្រឡះចេញ ទើបហៅថា "ស្ងប់ផ្លូវកាយ" គឺថា មិនមានក្តៅក្រហល់ក្រហាយអន្ទះអន្ទែងរសាប់រសល់ខ្វល់ក្នុងកាយ ។ សមនឹងព្រះពុទ្ធតម្រាស់ថា: ឧបសន្តោ សុខំ សេតិ "អ្នកស្ងប់រមែងដេកជាសុខ" គឺសុខគ្រប់អិរិយាបថទាំង ៤ ។

រួមសេចក្តីឲ្យខ្លីឆាយស្តាប់ទៅគឺថា បើយើងមិនបៀតបៀនគេ, មិនលួចទ្រព្យសម្បត្តិគេ, មិនប្រព្រឹត្តចំពោះប្រពន្ធកូនស្រីគេទេ, មិនជេរគេ. គេក៏មិនបៀតបៀន មិនលួចទ្រព្យសម្បត្តិយើង, មិនរវីរវាមនឹងយើង មិនជេរយើងវិញដែរ, ទាំងនាំឲ្យកើត មេត្តាធម៌, ទាំងករុណាធម៌ នឹងសន្តោស: សេចក្តីត្រេកអរតាមមានតាមបាន ដល់យើងផងទៀត ។ បើសិនជាយើង បៀតបៀនគេ លួចទ្រព្យរបស់គេ, ប្រព្រឹត្តខុសនឹងប្រពន្ធកូនគេ, ជេរគេ, គេក៏នឹងប្រព្រឹត្តរំលោភតបបែបនេះ

សងសឹកត្រឡប់មកលើយើងវិញពុំខាន ។ បុរាណសុភាសិតថា: យើងឲ្យទុក្ខគេ គេឲ្យទុក្ខយើង ។ សាសនធម៌ បញ្ជាក់ទៀតថា: ការបៀតបៀនវាក់កាប់សម្លាប់មនុស្សសត្វ លួចប្លន់គេ ប្រព្រឹត្តល្មើសនឹងប្រពន្ធកូនស្រីគេ ជេរប្រទេចគេ ឈ្មោះថា នាំឲ្យបែកបាក់មិត្តភាពនិងសាមគ្គីធម៌ ។ ត្រង់នេះហើយដែលហៅថា «ពៀរ» ប្រទូស្តទៅ ប្រទូស្តមកមិនស្ងប់ ម្ល៉ោះហើយចេះតែប្រឹងធ្វើបាបពេញបន្ទុកតាមតែអំពើចិត្ត ។ អ្នកណាស្វែងរកសុខដើម្បីខ្លួន ប៉ុន្តែជាអ្នកបៀតបៀនមនុស្សសត្វទាំងឡាយ ដោយអាជ្ញា អ្នកនោះរមែងមិនបានសេចក្តីសុខទៅមុខទេ ។ អ្នកណាស្វែងរកសុខដើម្បីខ្លួន ដោយមិនបៀតបៀនមនុស្សសត្វទាំងឡាយ ដោយអាជ្ញាទេ, អ្នកនោះទើបបានសុខទាំងលោកនេះ និងលោកខាងមុខ ។

បាប នេះ រមែងឲ្យទោសក្នុងលោកទាំងពីរ អ្នកធ្វើបាបក៏រមែងក្តៅក្រហាយក្នុងលោកទាំងពីរគឺ៖

១- ក្នុងលោកនេះ រមែងក្តៅក្រហាយដោយគិតថា អាត្មាអញបានធ្វើបាបដូច្នោះ ៗ ។

២- លុះច្យុតចាកលោកនេះទៅហើយ រឹងរឹតតែក្តៅក្រហាយជាងនេះទៅទៀត ។

សមដូចជាពុទ្ធោវាទទី ១ ថា: សត្វបាបស្ស អត្តារណាំ

ការមិនត្រូវធ្វើអំពើបាបទាំងពួង ( ដោយកាយវាចាចិត្តឬមិនប្រព្រឹត្តធ្វើខុស នឹងច្បាប់ផ្លូវលោកផ្លូវធម៌គ្រប់យ៉ាង ) ។ បុរសបុគ្គល ដែលត្រូវការដោយ សេចក្តីសុខចំរើន មិនគប្បីប្រព្រឹត្តធ្វើបាបឡើយ ! ។ ពុទ្ធោវាទនេះ បានដល់ព្រះវិន័យបិដកទាំងស្រុង ។ ព្រោះហេតុនោះ សាធុជនទាំងឡាយ អ្នកប្រាថ្នាសេចក្តីសុខចំរើនដល់ខ្លួននឹងអ្នកដទៃ មិនត្រូវធ្វើបាប ដែលជាអំពើលាមកថោកទាបយ៉ាងនោះទេ តែបើជនណាមួយ បាបស មនោមានះ នៅតែធ្វើបាបរឿយៗ នរជននោះឯង នឹងត្រូវបាន ទទួលរងសេចក្តីទុក្ខលំបាកយ៉ាងមហន្ត ទាំងក្នុងលោកនេះ ទាំងក្នុង លោកខាងមុខមិនលែងឡើយ ។ សមដូចជាព្រះគាថាក្នុងគម្ពីរធម្មបទដ្ឋកថា ត្រង់យមកវគ្គថា៖

ឥធ សោចតិ បេច្ច សោចតិ
បាបការី ឧភយត្ថ សោចតិ
សោ សោចតិ សោ វិហញ្ញតិ
ទិស្វា កម្មកិលិដ្ឋមត្តនោ ។

ប្រែថា: ជនអ្នកធ្វើកម្មអាក្រក់ តែងសោកស្តាយក្នុងលោកទាំងពីរ គឺក្នុងលោកនេះ ១, ក្នុងលោកខាងមុខ ១; ជនអ្នកធ្វើបាបនោះ តែង ក្តៅក្រហាយចិត្ត ព្រោះឃើញកម្មដ៏សៅហ្មងរបស់ខ្លួន ។

អធិប្បាយថា: បុគ្គលអ្នកធ្វើបាបកម្ម អំពើអាក្រក់គ្រប់យ៉ាង មាន.

ការសម្លាប់មនុស្សសត្វ លួចប្លន់ធុបាកគេ ប្រព្រឹត្តឈោះពុំគាប់ទីនឹបុរស ស្រីដែលមិនជាស្វាមី មិនជាភរិយារបស់ខ្លួន តែនឹកុហកគេក្តី ផឹកគ្រឿងស្រវឹងមានសុកជាដើមក្តី លុះដល់មរណសម័យពេលជិតស្លាប់ទៅក្នុងបច្ឆុប្បន្នជាតិនេះ ក៏ទៀនតែនឹទុក្ខសោកពុំដែលខាន ព្រោះឃើញជាការកុសលអាត្មាអញឥតបានធ្វើសោះ, អំពើដែលអាត្មាអញបានធ្វើរួចមកហើយនោះ សុទ្ធតែបាបកម្មទាំងអស់ ម្នោះហើយ ក៏កើតសេចក្តីក្តៅក្រហាយស្តាយក្រោយ ដោយព្រោយគំនិតមិនបានគិតកេសីលធម៌ជាទីពឹង រីតតែមានទុក្ខសោកក្រោកដេកបម្រះនេនៀលតាល់តែដាច់ជីវិតខ្ទើយស្លាប់អសារឥតការ ៗ ការសោកស្តាយបែបនេះ ហៅជានឹសោកព្រោះកម្ម ៗ លុះដល់ស្លាប់ទៅក៏នៅនឹផលវិបាក រឹសោកក្នុងបរលោកទៀត គឺទៅនេះ ទៅក្នុងក្ដើនទរកផ្ទប្រាកដពុំខាន ៗ បុគ្គលអ្នកធ្វើបាបនោះតែងតែរវើក់យក្តៅក្រហាយលំបាកក្នុងលោកទាំងពីរ ព្រោះឃើញកម្មដ៏សៅហ្មងរបស់ខ្លួនយ៉ាងនេះឯង ៗ ម្យ៉ាងទៀតក្តៅក្រហាយដោយស្តាយក្រោយថា៖ « អំពើដែលអញធ្វើរួចហើយ សុទ្ធតែជាអំពើបាបអាក្រក់ » ៗ លុះទៅកាន់ទុគ្គតិគត ក៏ក្តៅក្រហាយក្រៃលែងជាតិយេ្យកាតពជានេះទៅទៀត គឺថាបើទៅកើតក្នុងនរក ទៀនតែត្រូវនាយនិរយបាល-គាបគៀតចាក់កាប់ដោតថ្ពាន់ ចាប់បោះចុះទៅក្នុងរណ្ដៅរងើកភ្លើង បណ្ដេញឲ្យរត់ឡើងដើមរកាមានបន្លាស្រួចវែងមុតដូចដែក ឲ្យដេកត្រាំស្រះខ្ទុះក្នុងខ្ទះ

ទឹកចង់ដែងកំពុងពុះ ទីងគេបារៈរត់ចេញទៅណាពុំរួចជាដាច់ខាត ។

សេចក្ដីដូចបានពណ៌នាមកនេះ បើពុទ្ធបរិស័ទទាំងឡាយគ្រប់ជាន់ថ្នាក់ មិនមានការប្រព្រឹត្តិបៀតបៀនជិះជាន់គ្នានឹងគ្នា ដរាបណា ដរាបនោះ ពិភពលោកទើបបានសន្តិភាព ស្ងប់សុខសាន្តត្រាណរាបទាបដែរ ។ ការបលាបល ដោយទង្វាទវាត់កាប់សម្លាប់លួចប្លន់ឬបង្កភ្លើងសង្គ្រាមច្បាំងបាញ់គ្នាស្លាប់ពាសពេញដាសផែនប្រថពីពុំមានឡើយ ។ បើគេនៅតែមិនសុខចិត្តប្រព្រឹត្តគោរពសិទ្ធិនិងសេរីភាពឬតម្លៃរបស់មនុស្ស តាមច្បាប់លោកនិងច្បាប់ធម៌រៀង ១ ខ្លួន ដូច្នេះតើនឹងបានសុខសន្តិភាពមកពីណា ? មិនងាយបានសុខសន្តិភាពទេ ! ព្រោះគេមិនព្រមកាន់ក្រិត្យវិន័យរបស់ពុទ្ធសាសនា គ្រប់គ្នាទាំងអស់ ទើបបានជាមិនមានសុខសន្តិភាព ។ ព្រោះហេតុអ្វី ? ព្រោះមនុស្សក្នុងលោកសន្និវាស ក្រៅព្រះពុទ្ធសាសនាច្រើនក្រាស់ដោយ លោភៈ ទោសៈ មោហៈ ខ្លាំងណាស់ ! ។ បានជាមិនមានសន្តិភាព “ដំណើរស្ងប់ខាងផ្លូវកាយសោះ”

បើប្រសិនជា មនុស្សក្នុងសកលលោកនេះគ្រប់ជាតិ-សាសន៍-ភាសាគ្រប់ជាន់-ថ្នាក់នាំគ្នាជឿ កាន់តាមច្បាប់វិន័យរបស់ព្រះពុទ្ធជាម្ចាស់យើងដូចៗគ្នាទាំងអស់វិញ ដូចពោលមកថា សព្វបាបស្ស អករណំ សេចក្ដីថា: “ការមិនធ្វើអំពើអាក្រក់គ្រប់យ៉ាង” គឺថា អំពើបាបណាក៏ដោយឲ្យតែឈ្មោះថា លាមកអាក្រក់មិនត្រូវធ្វើ !, ម្ល៉េះសមពិភពលោកទាំងមូល

មានសន្តិភាពសុខសប្បាយគ្រប់ៗគ្នា, កាលបើគេនាំគ្នាប្រព្រឹត្តល្អធ្វើកាយវាចាចិត្តឲ្យស្ងប់តាមពុទ្ធោវាទនេះ កាលណា កាលនោះ គ្រឿងសស្ត្រាសម្រាប់ប្រហារមានកាំភ្លើងធំ-តូចជាដើម បែបណាក៏ដោយចុះ ទៀងតែសាបសូន្យអស់ពុំខានឡើយ ៗ

បើសន្តិភាពកើតមានក្នុងពារទក្ខត្តប្រទេសណា, ពារទក្ខត្តប្រទេសនោះមានសេចក្តីសុខបរិបូណ៌ពល់ៗប្រទេសក្នុងកាជនលោក ដោយពិតពុំខាន ៗ បើជាមនុស្សទាំងអស់អៀនខ្មាសជ្រេញអេរចំពោះអំពើទុច្ចរិតនោះៗ ងាកវិលមករកការកុសលកាន់សីលធម៌តាមព្រះពុទ្ធសាសនាគ្រប់ៗប្រទេស, ប្រាកដជាបានសន្តិភាព តែគ្រប់ៗប្រទេសពុំខាន ៗ សមគ្នានឹងពុទ្ធោវាទទី ២ ថា ៖ កុសលស្សូបសម្បទា ប្រែថា: ការបំពេញកុសលឲ្យបរិបូណ៌ គឺថា មានតែបុណ្យកុសលប៉ុណ្ណោះទេ ទើបឲ្យសុខជាផលកម្រៃ ៗ

ដូច្នេះ សប្បុរសទាំងឡាយគួរខំប្រឹងប្រែងព្យាយាមញ៉ាំងកុសលធម៌ឲ្យស្អាតផូរផង់ល្អជានិច្ចកាលឡើង ទើបបានឈ្មោះថាកាន់ព្រះពុទ្ធសាសនា បានទទួលលទ្ធផលដែលខ្លួនយើងថាជាអ្នកប្រកបដោយធម៌ ទាំងអ្នកដទៃក៏សុទ្ធតែជាអ្នកប្រកបដោយធម៌ដូចៗគ្នា ៗ បើយើងភាគតិចជាអ្នកធម៌អ្នកកាន់ច្បាប់ព្រះពុទ្ធសាសនាត្រូវហើយ ប៉ុន្តែពាស់នៅមនុស្សភាគ

ច្រើន ក្រៅចាកពុទ្ធសាសនា តើសុខសន្តិភាពរមែងចំរើនឡើងដូចម្តេចកើត ?

កាលបើពួកមនុស្សទាំងអស់ បានសុខចំរើនត្រេកអររីករាយ កើតទ្រព្យសម្បត្តិសម្បូរសប្បាយគ្រប់ៗប្រាណ ឥតមានទុក្ខទោសភ័យកំគិត តែបំពេញធម៌សុចរិតទាំងអស់ ទើបរីករាយត្រេកអរក្នុងលោកនេះ លុះទៅកាន់លោកខាងនាយ ក៏រមែងរីករាយត្រេកអររឹងរឹតតែក្រៃលែងជាងនោះទៅទៀត សមដូចពុទ្ធភាសិតថា ៖

ឥធ មោទតិ បេច្ច មោទតិ
កតបុញ្ញោ ឧភយត្ថ មោទតិ
សោ មោទតិ សោ បមោទតិ
ទិស្វា កម្មវិសុទ្ធិមត្តនោ ។

ប្រែថា: បុគ្គលអ្នកបានធ្វើបុណ្យទុកហើយ រមែងរីករាយក្នុងលោកទាំងពីរគឺ រីករាយក្នុងលោកនេះ ១, រីករាយក្នុងលោកខាងមុខ ១, បុគ្គលអ្នកធ្វើបុណ្យនោះ ។ រមែងរីករាយរឹងរឹតតែរីករាយយ៉ាងក្រៃលែង ព្រោះឃើញនូវអំពើដ៏បរិសុទ្ធស្អាតរបស់ខ្លួន ។

អធិប្បាយថា បុគ្គលណាបានធ្វើបុណ្យគ្រឿងផ្សេងៗ ដែលជាកាមាវចរកុសល គឺការបំរើមាតាបិតាគ្រូឧបជ្ឈាយាចារ្យ ទំនុកបំរុងអ្នកដែលគួរ

ទំនុកបំរុង សក្ការគុណថ្លៃល្អ ស្ដាប់ធម៌ទេសនា ឲ្យទានរក្សាសីល ចំរើនមេត្តាធម៌ បុគ្គលនោះរមែងរីករាយសប្បាយក្នុងជាតិនេះ ដោយពេញចិត្តចំពោះអំពើល្អដែលខ្លួនបានធ្វើហើយនោះថា: "អំពើអាក្រក់ៗអាត្មាអញមិនដែលធ្វើទេ, អំពើដែលអាត្មាអញបានធ្វើហើយ សុទ្ធតែអំពើល្អៗ មានប្រយោជន៍ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកៈដោយពិត" ។ រីករាយដូច្នេះ ឈ្មោះថា រីករាយព្រោះកុសលកម្ម ។ លុះដល់បុគ្គលនោះ ស្លាប់ខ្លួនទៅកាន់លោកខាងនាយ ក៏ទៀងតែរីករាយសប្បាយក្នុងពពួកទេវតា ព្រោះកើតឡើងពេលណា មានរូប, សំឡេង, ក្លិន, រស, សម្ផស្ស, អាយុ, ពណ៌សម្បុរ, សេចក្ដីសុខ, កម្លាំង, សេចក្ដីល្អាសរីរ សុទ្ធតែជាទិព្វទាំងអស់ ព្រមបានសួគ៌ទៅលោកនាយឯណោះជាប្រាកដ ។ សេចក្ដីរីករាយដូច្នេះឈ្មោះថា រីករាយព្រោះផលនៃកុសលកម្ម ។ បុគ្គលនោះរីករាយហើយនឹងតែរីករាយដោយក្រៃលែងក្នុងលោកទាំងពីរយ៉ាងនេះ ព្រោះឃើញអំពើរបស់ខ្លួនសុទ្ធតែបរិសុទ្ធហើយអំពើនោះឲ្យកម្រៃផលមក ក៏ជាទីពេញចិត្តបំផុតថែមឡើងទៀត ដូច្នេះឯង ។ បុគ្គលអ្នកធ្លាប់បានធ្វើបុណ្យតែងត្រេកអរក្នុងលោកទាំងពីរ គឺក្នុងលោកនេះ ត្រេកអរដោយនឹកឃើញថា "បុណ្យអញបានធ្វើទុករួចហើយ, លុះទៅកាន់លោកខាងមុខក៏បានទៅសោយទិព្វសម្បត្តិ ត្រេកអរក្រៃលែងក្នុងបុរីឈ្មោះតុសិតអស់ ៥៧ កោដិឆ្នាំនឹង ៦០ សែនឆ្នាំទៀត

ជាភាណក ។

លោកថា ខឹងខំអត់ ខ្សត់ខំរក មានបុណ្យមិនបេះខ្ទប មិនពុំផ្ទះមិនបេះក្រ បានធម៌ហើយ កុំគិតឡើយសម្បត្តិឥន្ទព្រហ្មរ៉ៃ ។ ពុទ្ធភាសិតថា បុគ្គលសាបព្រោះពូជបែបណា រមែងបានផលបែបនោះវិញ, អ្នកធ្វើល្អ រមែងបានផលល្អ, ឯអ្នកធ្វើអាក្រក់ រមែងបានផលអាក្រក់ ។

អ្នកបូជាគេរមែងបានការបូជាវិញ, អ្នកគំនាប់គាប់គួរគេ រមែងបានការគំនាប់គាប់គួរវិញ ។ អ្នកឲ្យសុខគេ រមែងបានសុខវិញ, ចំណែកខាងការឲ្យទុក្ខគេវិញសោត ក៏ដូចគ្នាដែរ ។

ដូច្នេះសាធុជនទាំងឡាយ អ្នកមានប្រាជ្ញាប្រាថ្នាសុខ- ចំរើន គប្បីខំស្វាហាប់បំពេញបុណ្យកុសលឲ្យបានច្រើនក្រៃលែងឡើង ហើយកុំគប្បីមានធម៌ប្រមាទកន្លងខានឡើយ យ៉ាងនេះឈ្មោះថា កាយសន្តិភាព ដំណើរស្ងប់ខាងផ្លូវកាយ ឬ សន្តិសុខ សុខដែលកើតអំពីសេចក្តីស្ងប់ (កាយ) ឬហៅថា កាយសោចេយ្យ ភាពជាអ្នកស្អាតកាយ ឬ កាយសាមគ្គី «សេចក្តីព្រមព្រៀងដោយកាយ» ។

# សុរពជាតក

(តចប់)

លោក ថង-វង ចម្លងពីសាស្ត្រាស្លឹករឹត

ក្ដាមដណ្ដឹងប្រស្នាចំពោះទន្សាយៗ ក៏ឆ្លើយពុំរួច, ទើបបបួលគ្នាទៅកាន់សំណាក់នាយព្រាន ៗ នាយព្រានក៏ឆ្លើយពុំបាន, បន្ទាប់មកក៏បបួលគ្នាទៅកាន់សំណាក់ស្វា ខ្លាធំ កិន្នរ ហើយដល់ទេវតា ៗ ផងទាំង ៧ នាក់នេះ ឆ្លើយពុំរួចដែរ ៗ

លំដាប់នោះ ក្អែកនឹងក្ដាមព្រមទាំងសំឡាញ់ ៧ នាក់ នាំគ្នាត្រាច់ត្រសងទៅរកគ្នាត ៗ ឯគ្នាតក៏ដោះស្រាយពុំត្រូវចិត្តក្ដាមឡើយ ៗ ទើបក្ដាមនិយាយថា ម្នាលគ្នាត! អ្នកដោះស្រាយប្រស្នាយើងពុំត្រូវឡើយ អ្នកដឹងថា សមណព្រាហ្មណ៍ ឬអ្នកប្រាជ្ញរាជបណ្ឌិតណាមួយ មាននៅក្នុងទីណាដែរឬ? ៗ គិជ្ឈា គ្នាតឆ្លើយថា ហៃក្ដាមមាស! ឥឡូវនេះ មានព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាមព្រះសុរពកុមារ ពហុបញ្ញា ព្រះអង្គមានព្រះប្រាជ្ញាច្រើន បណ្ឌិតោ ជាបណ្ឌិត បញ្ចកាមគុណំ បហាយ ទ្រង់លះបង់នូវកាមគុណ៥ ចេញទៅទ្រង់ព្រះផ្នួសនៅក្នុងព្រៃព្រះហិមពាន្ត, ដូច្នេះ យើងត្រូវនាំគ្នាទៅកាន់

សំណាក់ព្រះអង្គហោង ៗ សំឡាញ់ទាំងអស់ ក៏នាំគ្នាទៅកាន់សំណាក់ព្រះសុរេពតាបសនោះឯង ៗ តស្មឹំ ខណេ ក្នុងខណៈនោះ អស់ពពួកទេព្តាទាំងឡាយគឺ រុក្ខទេវតា អាកាសទេវតា ភូមទេវតា ទីងទេវតាដែលឋិតនៅក្នុងទីដទៃទៀតជាច្រើន នាំគ្នាមកប្រជុំគ្នា ចាំស្តាប់ការដោះអាថប្រស្នារបស់ព្រះមហាពោធិសត្វ ៗ ក្បែណនោះ សត្វទាំងឡាយមកដល់ហើយ ថ្វាយបង្គំនមស្ការ ព្រះសុរេពតាបស រួចហើយ អង្គុយនៅក្នុងទីដ៏សមគួរ ៗ ឯព្រះសុរេពតាបស លុះក្រឡេកឃើញសត្វទាំង ១០ នាំគ្នាមកដូច្នោះ ទ្រង់ញញឹមញញែមដោយព្រះតម្រិះថា ឥមេ អមិត្តា ជាតា រីសត្វទាំង ១០ នេះ ពីដើមមិនដែលឃើញជាមិត្តនឹងគ្នា, ឥឡូវនេះ មកជាមិត្តសំឡាញ់នឹងគ្នាដូច្នេះ តើមានហេតុអ្វី អេះ! អហោ អច្ឆរិយំ នុ! អស្ចារ្យណាស់ម្ល៉ា! ពួកទេវតាទាំងឡាយបបួលគ្នាមក មានរបើតាស់ទៃគ្នា ដោយហេតុអ្វីមួយ បានជាបណ្តើរគ្នាមកកាន់អាស្រមរបស់អាត្មាអញ ៗ កាលបើសត្វទាំងអស់មកដល់ហើយ ក៏ក្រាបទូលតាមដំណើរថា បពិត្រព្រះតាបស! រីក្អែកនឹងក្តាមពីរនេះតាស់ទៃគ្នា អំពីដំណើរក្តាមសួរប្រស្នាក្អែក, ឯក្អែកឆ្លើយពុំរួច ដូច្នោះបានជាហេតុនាំគ្នាមកកាន់សំណាក់ព្រះអង្គ ដើម្បីឱ្យព្រះអង្គដោះស្រាយ ៗ ព្រះតាបសសួរក្តាមថា អ្នកបាដណ្តឹងប្រស្នាមែនឬ? ៗ ក្តាមក្រាបទូលថា ខ្ញុំព្រះបង្គំបានដណ្តឹងប្រស្នា ២០ ចំពូកគឺ:

១– ទុក្ខដ៏ជាធំលើសទុក្ខទាំងពួង ក្នុងលោកិយនេះ គឺទុក្ខដូចម្តេច ?,

២– សុខអ្វីជាធំលើសសុខទាំងអស់ ក្នុងលោកនេះ និងបរលោក ?,

៣– បើបុគ្គលឃ្លាន បានបរិភោគផលប៉ុន្មានៗ ក៏ ពុំអាចនឹងបំបាត់ឃ្លានបាន តើអ្នកយល់ថា ឃ្លានអ្វី ?,

៤– ស្នេហ៍អ្វីល្អលើសស្នេហ៍ទាំងពួង ក្នុងលោកិយនិងបរលោក ?,

៥– អាក្រក់អ្វីលើសពីសម្បុរសៅហ្មងទៅទៀត ក្នុងលោកិយនិងបរលោក ?,

៦– អ្វីធំ ក្រៃលែងធំ ក្នុងលោកិយនិងបរលោក ?,

៧– អ្វីខ្ពស់ ក្រៃលែងខ្ពស់ ក្នុងឥធលោកនិងបរលោក ?,

៨– អ្វីក្តៅ ក្រៃលែងក្តៅ ក្នុងឥធលោកនិងបរលោក ?,

៩– អ្វីត្រជាក់ ក្រៃលែងត្រជាក់ ក្នុងលោកនេះ និងលោកខាងមុខ ?,

១០– អ្វីល្អិតសុខុមលើសគេដទៃ ក្នុងឥធលោកនិងបរលោក ?,

១១– ងងឹតអ្វីក្នុងលោកនេះ ព្រមទាំងលោកខាងមុខ លើសលែងជាងងងឹតទាំងអស់ ដែលហៅថា អតិតម ?,

១២– សភាពអ្វីរឹងរៀងធ្ងន់ធ្ងរ ក្នុងឥធលោកនិងបរលោក ?,

១៣- កូនខ្ញុំមកក្តី កូនសម្បកក្តី កូនស៊្លឹកក្តី ឬក៏ផ្ទនឹងផ្កាក្តី តើកូនអ្វី
ក្រអូបជាងកូន គន្ធជាតនេះ ?,

១៤- កូនអ្វីស្អុយជាងគេ ក្នុងលោកនេះ ?,

១៥- អ្វីខ្លាំងជាងគេ ក្នុងលោកនេះ ?,

១៦- អ្វីឆ្ងាយជាងគេ ក្នុងលោកនេះ ?,

១៧- អ្វីរហ័សជាងគេ ក្នុងលោកនេះ ?,

១៨- អ្វីប្រសើរជាងគេ ក្នុងលោកនេះ ?,

១៩- ខ្ញុំអ្វីប្រសើរ លើសខ្ញុំដទៃ ?,

២០- រសអ្វីប្រសើរជាងគេទាំងអស់ ?;

ប្រស្នារបស់ទូលព្រះបង្គំទាំង ២០ នេះ ផ្អែកឆ្លើយពុំបាន ទើបទូល
ព្រះបង្គំមកទូលសួរព្រះអង្គ ។

បពិត្រអើយ! ក្នុងកាលនោះ ព្រះបរមពោធិសត្វទ្រង់ត្រាស់សួរទៅ
ផ្អែកថា ម្នាលផ្អែក! អ្នកបានដោះស្រាយមែនឬ?, តើអ្នកដោះស្រាយ
ដូចម្តេចខ្លះ ? ។

ទើបផ្អែកក្រាបបង្គំទូលព្រះបរមពោធិសត្វ តាមលំដាប់នៃប្រស្នា
ដែលខ្លួនបានឆ្លើយតបទៅក្តាម គ្រប់ទាំង ២០ គឺ:

១- ផ្អែកណាដែលបុគ្គលកាត់ស្លាបកាត់កន្ទុយហើយ, ផ្អែកនោះ
ទឹងដល់ខ្ញុំសេចក្តីទុក្ខលើសអស់ទុក្ខទាំងពួង,

២- បើបុគ្គលណា បានបរិភោគសំឡញាំគ្នា ដែលបុគ្គលរៀបរណ្ដាប់ល្អហើយ ដកបឆ្អែតស្កប់ស្កល់ ដូច្នេះឈ្មោះថា ជាសុខលើសសុខទាំងពួង,

៣- បើអ្នកណាមួយអត់អាហារ គេពុំបាន លុះឃើញគេបរិភោគ ក៏មានសេចក្ដីស្រេកឃ្លានកើតឡើង នេះឈ្មោះថា អតិឆាតៈ,

៤- រស្មីដែលហូរចេញពីក្នុងព្រះអាទិត្យ ភ្លឺព្រោងព្រាតពេញទាំងអាកាស មានអ័ព្ទនឹងពពកប្រាសចេញអស់ ហៅថារស្មីល្អលើសរស្មីទាំងពួង,

៥- សត្វណាមួយ អត់អាហារពុំបានបាយទឹកបរិភោគ សម្បុរមែងស្រៅហ្មង ស្គាំងស្គមគាំក្រក់ណាស់ហោង,

៦- ថ្ងៃណាពុំមានវេទ ណែនគាំទល្អ នេះឈ្មោះហៅថា ធំលើសរបស់ទាំងពួង,

៧- អាកាសខ្ពស់លើសអ្វីទាំងពួង ក្នុងឥធលោកនឹងបរលោក គ្មានអ្វីខ្ពស់ជាងអាកាសឡើយ,

៨- ភ្លើងធម្មតាក្ដៅពុំស្មើនឹងភ្លើងនរក ភ្លើងនរកក៏ក្ដៅពុំស្មើនឹងភ្លើងកល្ប ភ្លើងកល្បនេះឈ្មោះថា អតិឧណ្ហៈហោង,

៩- ទឹកក្នុងត្រជាក់លើសអ្វីទាំងអស់ក្នុងលោកនេះ នឹងលោកខាងមុខ,

១០- វត្ថុល្អិតសុខុមលើសអ្វីទាំងអស់ គឺខ្យល់,

១១- ងងឹតក្នុងរាត្រី មានពពកអ័ព្ទអន្ធការ ពុំមានរស្មីព្រះចន្ទនិងផ្កាយ ឈ្មោះថា ងងឹតក្រៃលែងជាងងងឹតអ្វីទាំងអស់,

១២- ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿងក្នុងពេលរាត្រី រស្មីទាំងពីរនេះ រុងរឿងជាងអ្វីទាំងអស់,

១៣- បណ្ដាគន្ធជាតទាំងអស់ មានសម្បកនិងខ្លឹមឈើជាដើម ពុំស្មើនិងក្លិនសាបជាទីត្រេកចិត្តសត្វទាំងឡាយឡើយ ព្រោះក្លិននេះ ក្រអូបលើសលែងក្លិនទាំងពួង,

១៤- លាមកមនុស្សស្អុយជាងគេ ក្នុងលោកនេះ,

១៥- ព្រះនារាយណ៍ខ្លាំងជាងគេ ក្នុងលោកនេះ,

១៦- ចក្រវាឡឆ្ងាយលើសអ្វីទាំងអស់ សត្វបក្សីបក្សាហើរទៅពុំដល់ឡើយ,

១៧- ខ្យល់ព្យុះសង្ឃរាហ័សជាងអ្វីទាំងអស់,

១៨- ព្រះឥន្ទ្រាធិរាជប្រសើរជាងគេទាំងអស់,

១៩- ភ្នំមានខ្លឹមលើសអ្វីៗទាំងអស់ ព្រោះខ្យល់បក់មកក្ដី ភ្លើងព្រៃក្ដី ពុំអាចធ្វើភ្នំឲ្យវិនាសបានឡើយ,

២០- រសបាយៈភាជសាលីនិងសាច់ ប្រសើរជាងរសទាំងអស់ ។

បពិត្រព្រះតាបស ! ខ្ញុំព្រះអង្គ បានឆ្លើយប្រស្នានេះតបទៅតាម ៗ

ក្បួនណានោះ ព្រះមហាបុរសទ្រង់ត្រាស់ទៅកាន់គាមថា ប្រស្នា

នេះល្អិតសុខុមណាស់ កាលណាក្អែកឆ្លើយត្រូវ ចូរអ្នកទាំងឡាយ

ចាំស្តាប់យើង ៗ នឹងដោះស្រាយ ៖

១- ទុក្ខដ៏ជាធំលើសទុក្ខទាំងពួងក្នុងលោកៈនេះនឹងបរលោក បាន

ដល់ទុក្ខ ៨ ប្រការគឺ: ជាតិទុក្ខ ១, ជរាទុក្ខ ១, ព្យាធិទុក្ខ ១,

មរណទុក្ខ ១, បិយេហិ វិប្បយោគទុក្ខ ទុក្ខកើតអំពី

ការព្រាត់ប្រាសចាកវត្ថុរបស់ជាទីស្រឡាញ់ ១, អប្បិយេហិ, សម្ប-

យោគទុក្ខ ទុក្ខកើតអំពីការជួបប្រទះនូវវត្ថុដែលមិនជាទីស្រឡាញ់ ១,

យម្បិច្ឆំ ន លព្ភតិ តម្បិ ទុក្ខ ទុក្ខកើតអំពីការប្រាថ្នាវត្ថុអ្វីមួយ

មិនបាននូវវត្ថុនោះដូចបំណង ១, សង្ខិត្តេន បញ្ចុបាទានក្ខន្ធា

ទុក្ខដោយបំព្រួញបានដល់សេចក្ដីទុក្ខ ដែលកើតអំពីឧបាទានក្ខន្ធទាំង

ប្រាំ ១; ទុក្ខទាំង ៨ ប្រការនេះ ឈ្មោះថា ជាទុក្ខលើសអ្វីទាំងអស់ ៗ

វិសេសទាំងអស់មានក្អែកនឹងក្ដាមជាដើម ព្រមទាំងទេវតាប្រមាណ ១

សែនក៏ឲ្យពរសាធុការឮសូរទ្រហឹងអឹងកងពេញទាំងព្រៃព្រឹក្សា ៗ

២- សុខជាធំលើសសុខទាំងពួង បានដល់សេចក្ដីសុខរបស់

បុគ្គលដែលបានស្ដាប់ធម៌ ឬបានឃើញធម៌ ហើយមានចិត្តត្រេកអរ

សាទរ ជាអ្នកមានចិត្តប្រាសចាកកាមគុណទាំង ៥ ចេញទៅបួស ក្រោកអរតែក្នុងធម៌ម្យ៉ាង, សេចក្ដីសុខដូច្នេះ ឈ្មោះថាជាសុខលើសសុខទាំងអស់ក្នុងលោកនេះ ព្រមទាំងលោកខាងមុខ ។

៣- បុគ្គលអ្នកឃ្លាន ពោះបើបានបរិភោគបន្តិចបន្តួច ក៏គ្រាន់តែគ្មានបំបាត់នូវសេចក្ដីស្រេកឃ្លានបាន, បានដល់បុគ្គលអន្ធពាល ចិត្តបាបមិច្ឆាទិដ្ឋិធ្វើបាបកម្មផ្សេងៗ ហៅថាពុំចេះឆ្អែតឆ្អន់, ម្យ៉ាងទៀតបានដល់បុគ្គលអ្នកសេពកាមគុណ ក៏ពុំចេះឆ្អែតឆ្អន់ដែរ ។

៤- រស្មីព្រះអាទិត្យក្ដៅតែក្នុងពេលថ្ងៃ រស្មីព្រះចន្ទក្ដៅតែក្នុងពេលរាត្រី ពុំអាចភ្លឺចូលទៅក្នុងលោកខាងមុខបានឡើយ, រស្មីគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រមែងភ្លឺរុងរឿងទាំងពីមនុស្សលោក ព្រហ្មលោក រហូតដល់ព្រះនិព្វានជាទីបំផុត, មួយទៀត បានដល់រស្មីគឺប្រាជ្ញា ព្រោះប្រាជ្ញាជាធម្មជាតិអាចភ្លឺឃើញ បាប បុណ្យ គុណទោស ប្រយោជន៍ និងមិនមែនប្រយោជន៍ ទីបំផុតបានដល់ប្រាជ្ញាដែលពិចារណាឃើញព្រះត្រៃលក្ខណ៍ទាំង ៣ គឺ ទុក្ខំ អនិច្ចំ អនត្តា ដូច្នោះបានជាថា រស្មីនេះវិសេសលើសរស្មីទាំងពួង ។

៥- បុគ្គលជាមិច្ឆាទិដ្ឋិប្រព្រឹត្តធ្វើតែអំពើទាំង ៥ គឺ: បាណាតិបាត ១, អទិន្នាទាន ១, កាមេសុមិច្ឆាចារ ១, មុសា ១, សុរា ១;

បុគ្គលដែលមានចិត្តជាប់ដោយអំពើអាក្រក់ទាំង ៤ ប្រការនេះ រមែងខ្ពើមឆ្អើមចំពោះអំពើជាកុសល, ដូច្នេះឈ្មោះថា មានសម្បុរសៅហ្មង, លើសការសៅហ្មងទាំងអស់ ។

៦- ចិត្តរបស់សត្វទាំងឡាយ ឈ្មោះថា ធំ លើសអ្វីទាំងអស់ បុគ្គលអ្នកធ្វើនូវអំពើជាកុសលក្តី អកុសលក្តី មានចិត្តជាអ្នកដឹកនាំ ។

៧- មនុស្សក្នុងលោកខ្ពស់លើសអបាយភូមិទាំង ៤, ទេវលោកខ្ពស់លើសមនុស្សលោក, ព្រហ្មលោកខ្ពស់លើសទេវលោក; រីឯព្រះនិព្វានខ្ពស់លើសគេទាំងអស់ ព្រោះព្រះនិព្វាន មិនអាចនរណាមួយទៅបានដោយជិះ សេះ រថរទេះ, គេទៅបានដោយអដ្ឋង្គិកមគ្គ ទើបដល់ព្រះនិព្វាន ។

៨- ភ្លើងធម្មតាក្តី ភ្លើងនរកក្តី ភ្លើងកល្បក្តី តែងដុតសត្វទាំងឡាយ តែមួយពេលមួយខណៈប៉ុណ្ណោះ ឯភ្លើងក្តៅជាងនេះទៅទៀត បានដល់ រាគគ្គិ ភ្លើងគឺរាគៈ, ទោសគ្គិ ភ្លើងគឺទោសៈ មោហគ្គិ ភ្លើងគឺមោហៈ, ភ្លើងទាំង ៣ គត់នេះ រមែងដុតកំដៅចិត្តសត្វនូវទៅឥតស្រាកស្រាន្ត ធ្វើឲ្យសត្វក្នុងលោកនេះអន្ទះអន្ទែងគ្រប់ទិភពត្រៃ ។

៩- វត្ថុសម្រាប់ធ្វើឲ្យត្រជាក់ មានទឹកនិងខ្យល់ជាដើមក្នុងលោក

នេះ ពុំស្មើនឹងធម៌ជាពុទ្ធភាសិត ដែលព្រះសម្ពុទ្ធទាំងឡាយសំដែងទុកមកឡើយ ។ ធម៌ដែលជាពុទ្ធភាសិតនោះមាន ៧ យ៉ាងគឺ: ការចិញ្ចឹមនូវមាតាបិតា ១, ការប្រព្រឹត្តិកោតក្រែងចំពោះត្រកូលរៀមច្បងម្ចាស់ព្រឹទ្ធាចារ្យ ១,ពោលសំដីផ្អែមពីរោះចំពោះពៅអ្នកផង ១, មិននិយាយសំដីចាក់ដោតអ្នកដទៃ ១, មិនមានសេចក្ដីកំណាញ់ ១, និយាយតែសំដីទៀងទាត់ ១. បំបាត់សេចក្ដីក្រោធខឹងបាន ១ ។ ធម៌ទាំង ៧ យ៉ាងនេះ ឈ្មោះថាត្រជាក់លើសវត្ថុដទៃទាំងអស់ ។

១០- ទឹកល្អតជាងខ្យល់និងកំដៅថ្ងៃ ទឹកភ្លៀងល្អតលើសទឹកធម្មតា ទឹកឧត្តមមហាសមុទ្រល្អតលើសទឹកភ្លៀង ទឹកដោះកេសរសីហ៍ល្អតលើសទឹកឧត្តមមហាសមុទ្រ, ឯទឹកដោះកេសរសីហ៍ពុំល្អតស្មើនឹងធម៌ជាពុទ្ធ-ភាសិតឡើយ; ធម៌ទាំងឡាយជាសភាវៈល្អតដ៏លើសអ្វីទាំងអស់, កម្រមនុស្សយល់បាន រះស្កាប់, មានតែអ្នកប្រាជ្ញទេបលោកយល់បាន ។

១១- ងងឹតកន្ទុំពេលកត្រពុំមានព្រះចន្ទនឹងផ្កាយ ពុំស្មើនឹងការងងឹតក្នុងលោកន្តរនរក, ប៉ុន្តែ ការងងឹតលើសអ្វីទាំងអស់ បានដល់-ការងងឹត ៣ ប្រការគឺ: ងងឹតដោយអវិជ្ជា ១, ងងឹតដោយមោហៈ១, ងងឹតដោយទិដ្ឋិ ១; ងងឹតទាំង ៣ នេះឈ្មោះថា ងងឹតជាងការងងឹតអ្វីទាំងអស់ ។

១២- ពន្លឺព្រះអាទិត្យក្តី, ពន្លឺព្រះចន្ទក្តី ពុំដល់ពន្លឺរបស់អ្នកមានប្រាជ្ញាទាំងឡាយឡើយ, ព្រោះជនអ្នកមានប្រាជ្ញារមែងមានពន្លឺរុងរឿង អាចពិចារណាឃើញបាបបុណ្យគុណទោសទាំងអស់ ។

១៣- ក្លិនគន្ធជាតទាំងឡាយក្នុងលោកនេះ មានខ្លឹមច័ន្ទក្រស្នាជាដើម ដែលមនុស្សលោកសន្មតថា មានក្លិនក្រអូបលើសអ្វីទាំងអស់, ក្លិនគន្ធជាតនេះ ពុំអាចក្រអូបច្រាសខ្យល់បានទេ; ចំណែកខាងក្លិនរបស់សីល រមែងក្រអូបផ្សព្វផ្សាយទូទៅ ក្នុងមនុស្សលោកនិងទេវលោក ។

១៤- បុគ្គលណាមួយ ប្រព្រឹត្តអំពើអាក្រក់ មានកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតជាដើម ឈ្មោះថា ស្អុយក្នុងលោកនេះនិងលោកខាងមុខ ។

១៥- វត្ថុដែលខ្លាំងជាងគេក្នុងលោកនេះ ពុំមានអ្វីស្មើនឹងមច្ចុរាជ (សេចក្តីស្លាប់) ឡើយ, ព្រោះមច្ចុរាជអាចទំពាស៊ីមនុស្សលោក ទេវលោក ព្រហ្មលោក ពុំមានអ្នកណាមួយតតាំងច្បាំងនឹងមច្ចុរាជនេះបានឡើយ ។

១៦- ព្រះនិព្វានជាធម្មជាតឆ្ងាយជាងអ្វីទាំងអស់ ។

១៧- ចិត្តរបស់មនុស្សយើងរហ័សជាងអ្វីទាំងអស់ ។

១៨- របស់ដែលប្រសើរជាងគេទាំងអស់មាន ៧ យ៉ាងគឺៈ- សទ្ធា ជឿរបស់ដែលគួរជឿ ១, សីល រក្សាកាយវាចាឲ្យរៀបរយល្អ ១, ហិរិ សេចក្ដីខ្មាសអំពើបាប ១, ឱត្តប្បៈ សេចក្ដីខ្លាចអំពើបាប ១, សុត ជាអ្នកបានឮបានស្ដាប់ច្រើន ជាអ្នកចេះចាំធម៌និងវិជ្ជាសិល្បៈច្រើន ១, ចាគៈ ការបែងចែកទ្រព្យរបស់ខ្លួនឲ្យដល់បុគ្គលដែលគួរឲ្យ ១, បញ្ញា សេចក្ដីដឹងស្គាល់របស់ដែលជាប្រយោជន៍ មិនមែនជាប្រយោជន៍ ១; គុណទាំង ៧ ប្រការនេះ ប្រសើរជាងទ្រព្យដទៃមានមាសពេជ្រជាដើម ។

១៩- ខ្ញុំមរក្ខជាតិដទៃ ។ ពុំស្មើនឹងខ្ញុំមកុសលធម៌ទេ, កុសលធម៌នេះ បានដល់ទាន ១, សីល ១, ភាវនា ១ ។

២០- រសរបស់ធម៌ ប្រសើរជាងរសដទៃទាំងអស់ ។

កាលបើព្រះសុគតបានដោះស្រាយប្រស្នាទាំង ២០ ចប់សព្វគ្រប់ហើយ, រីអស់ទេវតាព្រមទាំងសត្វទាំងឡាយ លើកអញ្ជលីស្រែកហ៊ោថ្វាយសាធុការពរចំពោះព្រះបរមពោធិសត្វ ខ្លះថ្វាយកម្រងមាលា ខ្លះថ្វាយទូរគន្ធៈផ្សេង ៗ រួចហើយវិលទៅលំនៅឋានរៀង ៗ ហោង ។ ឯក្ដាមមានចិត្តត្រេកអរសាទរផុតឧបមាបីតនៅក្នុងចំពោះព្រះបរមពោធិសត្វ ទ្រង់ឲ្យក្ដាមសមាទានសីល៥ ហើយត្រាស់ទៅកាន់

កាមថា: ម្នាលកាម ! អ្នកកុំទៅកាន់ដែនរបស់មនុស្សឡើយ ចូរទៅគង់ស្រះធំនេះចុះ ។ កាមក្រាបទូលថា បពិត្រព្រះតាបស ! ទូលបង្គំមានបុរសម្នាក់ជាអ្នកចិញ្ចឹមរក្សា, កាលដែលទូលព្រះបង្គំមកកាន់ទីនេះ ទូលព្រះបង្គំបានដកបគាត់តាមដំណើរ, ដូច្នេះ គួរទូលព្រះបង្គំក្រាបថ្វាយបង្គំលាព្រះអង្គទៅកាន់សំណាក់គាត់វិញ ។ គ្រានោះ ព្រះបរមពោធិសត្វទ្រង់បង្គាប់ទៅក្អែកថា: ម្នាលក្អែក ! ដូច្នេះ អ្នកចូរនាំកាមទៅកាន់បុរសជាបិតាកាមវិញចុះ ។ ក្អែកព្រមហើយ ក៏នាំកាមទៅកាន់សំណាក់បុរសនោះវិញ ។ ឯបុរសនោះ ឃើញក្អែកនាំកាមមកដូច្នោះ ក៏ឲ្យបាយចំណីដល់ក្អែកស៊ីឆ្អែតស្កប់ស្កល់ ហើយក្អែកសុំលាទៅលំនៅរបស់ខ្លួន, ទើបបុរសនោះផ្ដាំថា បើអ្នកឃ្លានពុំមានអាហារបរិភោគ ចូរអ្នកមកបរិភោគជាមួយនឹងយើងហោង ។ ឯព្រះសុរពតាបសលុះអស់អាយុពីមនុស្សលោកនេះទៅ បានទៅកើតក្នុងព្រហ្មលោកនាយ ។

សត្ថា រីសម្ដេចព្រះបរមសាស្ដា លុះទ្រង់សំដែងធម៌ទេសនាចប់ហើយ ព្រះអង្គទ្រង់ប្រមូលមកទូវជាតកថា: ភិក្ខវេ ម្នាលភិក្ខុសង្ឃទាំងឡាយអើយ ! តថាគតមិនមែនមានប្រាជ្ញាតែក្នុងកាលដែលតថាគតបានត្រាស់ប្រាជ្ញាសព្វញ្ញុតញ្ញាណហើយទេ កាលពីដើមក៏តថាគតមានប្រាជ្ញាដែរ, ស្រេចហើយព្រះអង្គទ្រង់ត្រាស់តទៅទៀតថា:

តទា សុវណ្ណកក្កដោ រីក្ដាមមាសក្នុងកាលនោះ បាន

មកជាពហុលត្ថេរក្នុងកាលឥឡូវនេះ, ក្អែកក្នុងកាលនោះបានមកជាអង្គុលិមាលត្ថេរក្នុងកាលឥឡូវនេះ, ពានរក្នុងកាលនោះបានមកជាលោលុទាយិត្ថេរក្នុងកាលឥឡូវនេះ, កិន្នរក្នុងកាលនោះ បានមកជាភិក្ខុកស្សបៈក្នុងកាលឥឡូវនេះ, ព្រះឥន្ទ្រ បានមកជាភិក្ខុឈ្មោះអនុរុទ្ធ ក្នុងកាលឥឡូវនេះ, នាគបានមកជាភិក្ខុមោគ្គល្លានក្នុងកាលឥឡូវនេះ, ព្រះពិស្ណុការ បានមកជាភិក្ខុឆន្នៈក្នុងកាលឥឡូវនេះ, ព្រះមាតាព្រះបិតារបស់តថាគតក្នុងកាលនោះ បានមកជាព្រះមាតាព្រះបិតារបស់តថាគតដដែល ព្រះសោរតកុមារដ៏ជាព្រះអនុជតថាគត បានមកជាភិក្ខុអានន្ទ, ឯព្រះសុវតតាបស អហាមេវ គឺតថាគតហ្នឹងឯង សម្មាសម្ពុទ្ធោ បានត្រាស់ដឹងនូវប្រាជ្ញាសព្វញ្ញុតញ្ញាណ ជាទីពឹងពំនាក់របស់ទេវតានិងមនុស្សទាំងឡាយ ៗ

សុវតជាតកចប់តែប៉ុណ្ណោះ

---

# ផ្នែកអក្សរសាស្ត្រ

## រឿងហង្សយន្ត

(តមក)

លោក អ៊ឹម-កន បម្លងពីសាស្ត្រាស្លឹករឹត

ទេវីក្សត្រីកញ្ញា នាងយកចម្ប៉ា នៃបនឹងរំដួល ៗ នាងក្រងទាំងចង ផ្តោល ជារូបស្រីស្ងួន សោតសឹងរេកំ ៗ កែក្រាយផ្កាបទន្ទាំ បាទបទលំនាំ ទន់ក្ងន់ផ្កាស្រី ៗ នាងក្រងកម្រងមួយទី នាងយកមាលតី នៃបនឹងស្រលិត ៗ នាងក្រងកម្រងផ្គួកផ្គិត ជាបក្សីសត្វ គឺហង្សមាសមៃ ៗ ទំនាក្រុងក្រពឹក្សព្រៃ ហាក់សេវិស័យ ចឹកចាប់បុប្ផា ៗ នាងក្រងកម្រងមួយណា នាងយកក្តាំងផ៉ា នៃបនឹងមហាហង្ស ៗ នាងក្រងទាំងចងសោតផ្គង់ ជារូបពជហង្ស ហើរពាំភ្ញីមាស ៗ នាងក្រងផ្កាផងឆ្នុះឆ្នាស យកំរេដេញមាស នៃបនឹងត្រយង់ ៗ នាងក្រងទាំងចងជាគង់ ក្អែកមាសពេនពង់ យានយាសរេក ៗ នាងក្រងកម្រងមួយណា នាងយកយុក្កា អញ្ចូនប្បារប្រាល ៗ នាងក្រងផ្កាផងត្រកាល ជារូបសេកសា-រិកាពាំក្បី ៗ នាងក្រងកម្រងមួយទី នាងយកនួនស្រី កែស្រស់កេសរ ៗ

នានក្រិនកម្រងបវរ ជារូបកិន្នរ ទ្រើសទ្រនំថ្ងាំ ៗ តែក្រោយ
ផជាយរើក យានយាសខ្ញុំ ខ្នេងបាឧបខ ៗ នានក្រិនកម្រង
ក្រពុំកដ ជារូបស្តេចគ្រុឌ ធៀងធាបនាគា ៗ នានក្រិនកម្រងមួយ
ណា សុពណ៌គេត្រា បើកជូនផ្ទុកផ្ទោះ ៗ នានក្រិនកម្រងមួយ
នោះ សន្មតនាមឈ្មោះ មាលាសិរសី ៗ ក្សត្រក្សាប់រំលេចសិនក្បី
ព្រើនពណ៌ពិសី ពិសេសសោភា ៗ នានក្រិនផ្កាផងនានា ប្រសើរ
ជាតិជា ក្រកាលពេកពន់ ៗ ដូចគាសោតណាសិងគន់ យល់នាន
ស្រីគន់ ក្រិនផ្កាល្អក្រៃ ៗ ដូនតាថ្លែងថាមាសថ្លៃ មានប្រាជ្ញាវៃ
លើសលែងលោកផង ៗ ក្សត្រីក្រិនក្បីឥតគ្គង សុរេបហើយហាន
ទើបយាយមាលា ៗ នាំក្បីឃ្លាតខ្មីយាត្រា ទៅដល់រាជា ក្រាបទូល
ថ្វាយហាន ៗ ក្សត្រថ្លៃប្រពៃឥតគ្គង ទតយល់កម្រង ផ្កានោះល្អ
ក្រៃ ៗ ព្រះបាទនរនាថជៀសជ័យ សព្វព្រះហឫទ័យ នឹងផ្កានេះ
ណាស់ ៗ ពុំលន់ព្រះអង្គស្តេចត្រាស់ ដណ្តឹងដូចចាស់ គឺយាយ
មាលា ៗ ព្រះស្នូរបន្ទូលត្រាស់ថា ដូចអើយនរណា ក្រិនផ្កាថ្លៃខ្ទះ
ល្អម្តេចចំឡែកដល់ម្ល៉េះ កម្រងផ្កានេះ មិនតីយាយក្រិន ៗ ទើបយាយ
អតិប្រាយឥតគ្គង បង្គំទូលស្នង ព្រះបន្ទូលថា ៗ បពិត្រសម្តេចរាជា
ចៅខ្ញុំមួយណា ប្តីរាលែងចង់ ៗ តែជាជៀតវាពុំចង់ ធ្វើការគ្គត់គ្គង់
រកស៊ីឡើយណា ៗ ហើយចង់តែស្អាងអាត្មា គឺមោះរូបអា- ក្រក់ក្រៃ

ពេកពន់ ៗ រូបស្អាតស្រស់ត្រគាកត្រេង ភក្រក់លើសលន់ ក្រៃ
លែងអស់ស្រី ៗ សរីរល្អឆ្លាញខ្លួនអប្រិយ ហេតុនោះទើបប្តី ពៅ
លែងចង់បោះ ៗ ពិតពីកាលប្តីពៅនោះ ឆ្នាំមួយស៊ូឲ្យសោះ ឃ្លាយ
ខែផងណា ៗ ពៅមកត្រាច់រកខ្ញុំជា ជីជូនហើយពៅ ទៅទីខ្ញុំហោង ៗ
ខ្ញុំឯងគាក់តែងឲ្យក្រង ផ្កានេះជាម្ដង មកថ្វាយក្សត្រថ្ងៃ ៗ បើពៅក្រង
ផ្កានេះនៃ សព្វព្រះហឫទ័យ ខ្ញុំអរគ្គាត់ណា ៗ ហើយខ្ញុំទូលសូម
ក្រាបលា ឲ្យទៅខ្ញុំពៅ ក្រងតាងខ្ញុំហោង ៗ ទើបមហាក្សត្រាច្បាស់
ច្បង ស្ដេចបន្ទូលផង ទៅយាយមាលា ៗ អញស្ដាយទៅយាយនេះ
ណា ចេះជាងក្រងផ្កា ត្រកាលក្រមាន ៗ ខុសដ្បិតគំនិតពុំបាន ចរ-
យាបថគ្មាន រូបភក្រកក្រៃ ៗ ទីងយកពៅមកនៅនៃ ក្នុងផ្ទះសព្វ
ថ្ងៃ ពុំបានឡើយហោង ៗ ពីថ្ងៃនេះទៅជាម្ដង យាយឲ្យពៅក្រង តាង
យាយហោងណា ៗ ក្សណក្សត្រមែនមានមេត្តា ស្ដេចឲ្យប្រព្យា
កែរកងគ្រប់គ្រាន់ ៗ ក្សត្រថ្ងៃប្រសើរសោភ័ណ ស្ដេចឲ្យផ្ញើន់ នៃ
យាយមាលា ៗ យាយបានប្រទានក្សត្រា បង្គំក្រាបលា ទៅផ្កាឧបាន
ឋិត ៗ ប្រដាប់ស្រេច ហើយជញ្ជូត ព្រលឹងទៅថ្វាត់ ពុំលង់ឡើយ
ហោង ៗ ស្រីថ្ងៃប្រពៃគន្ធង នាងនាថនៅជង ទីងយាយមាលា ៗ
ជួយចប់គំរប់ជាក់ជា សោឡសវស្សា បរបូណ៌ហើយនៃ ៗ ក្សត្រី
ក្រងគ្រឿសព្វថ្ងៃ ថ្វាយមហាក្សត្រថ្ងៃ នូវរាជបុត្រា ៗ នាងបានប្រទាន

ក្សត្រា ចិញ្ចឹមគាត្ថា ជាប្រក្រតីហោង ។ យើងស្វះសំដែងដោយ
ជង ដំណើរទំនង វរកជក្សត្រី ។ នៅនេះយើងស្វះក្សិណខ្ញី ហើយ
យើងថ្វាយពី ព្រះបាទព្រហ្មទត្ត ។ ព្រះអង្គទ្រង់ធម៌ពេកក្តាត់ រើស
រាជបុត្ររៀន នាងនាថមិញណា ។

## បទកាកគតិ

នេះនឹងថ្វាថ្វៃង បទកាកគតិតែង និទានដំណាល ដំណើរអំពី
ព្រហ្មទត្តភូបាល រើសបុត្រគ្រកាល ក្រោមដើមក្រែស្នា ។

កាលនោះព្រះបាទ សម្តេចនរនាថ ព្រហ្មទត្តរាជា បានរាជកុមារ
ព្យាបាលកេរ្ត៍ បានបរិបូណ៌ជា សោឡសឆ្នាំខែ ។ ទៅក្រែស្នកុមារ
បរិបូណ៌ពេញពាល ទ្រង់នាមប្រពៃ ព្រះវរបិតា ករុណាពេកក្រៃ
ខឹងឲ្យគ្រងផ្ទៃ ក្រោមតានរាជា ។ កាលនោះព្រះបាទ ត្រាស់ប្រើសេវាមាត្យ
ចរចេញមិម្មា ប្រាប់អស់ក្សត្រជង គ្រប់គ្រងសីមា ចំណុះរាជា
តាំងយេងកអង្គ ។ ឲ្យរើសបុត្រី មុខមាត់ប្រិមប្រិយ សោភសិរីតែងអង្គ
គ្រឿងគ្រប់ប្រដាប់ ស្រេចស្រាប់គ្រប់អង្គ នាំមកពុំលង់ ថ្វាយព្រះ
ភូបាល ។ ស្ដេចនឹងឲ្យជា ព្រះរាជជាយា ទៅក្រែស្នកុមារ តាមសព្វ
ព្រះទ័យ បុត្រថ្វៃសន្សារ រើសរាជកញ្ញា មួយមួយឯណា ។
នោះទើបសេវាមាត្យ ខុនអភិរាម បង្គំក្រាបលា នាំព្រះឧង្ការ រាជសារ

ទៅថា នីងអស់ក្សត្រា សព្វគ្រប់ហើយនៃ ៗ អស់ស្តេចស្តែងស្តាប់
ព្រះអាជ្ញាប្រាប់ ម្នីមាវៃ តែងតួក្សត្រី ឃាតខ្ទីងាប់ក្រៃ ដោយ
តួទៃរ នាំចូលទៅថ្នាក់ ៗ ដល់ជុំពុលង់ ទាំងរយឯកអគ្គ សីងនារី
រតន៍ ទ្រង់គ្រឿងប្រដាប់ ស្រេចស្រាប់ពេកក្តាត់ នាំថ្វាយមហាក្សត្រ
ព្រហ្មទត្តពជា ៗ ក្សិណក្សត្រដៀស្តជ័យ ឲ្យហៅបុត្រថ្លៃ ទតអស់
ធីតា ទៅក្រឹស្នកុមារ ត្រអាលម្និមា ទតអស់កញ្ញា បុត្រីក្សត្រផង ៗ
ទតគ្រប់ហើយនៃ ពុំសព្វព្រះទ័យ ដល់មួយជាម្តង អស់ពជធីតា
ក្រាបលាទៅហោង វិលវិងទៅផ្គង ស្រុកទេសទីទៃ ៗ ក្សិណនោះ
ព្រះបាទ ព្រហ្មទត្តនរនាថ ធិពជជៀស្តជ័យ ស្តេចបើកព្រះសូរ
បន្ទូលថាហៃ កូនស្ងួនថ្លើមថ្លៃ ពន្លកបិតា ៗ កូនអើយហេតុអ្វី
អស់ទាំងនារី រយឯកអគ្គា ក៏កូនពន្លក ពុំយកនាងណា ដល់
មួយជាតិជា អយិអគ្គមហេសី ៗ ទៅក្រឹស្នកុមារ បុត្រស្ងួនសង្ស៊ារ
ថ្វាយបវរទ្ទីយ ទូលថាបពិត្រ សម្តេចកូមី ខ្ញុំមើលអស់ស្រី អស់បុត្រ
ក្សត្រផង ៗ ខ្ញុំមើលមិនពេញ ចិត្តមិនស្រឡាញ់ ដល់មួយឡើយ
ហោង សព្វថ្ងៃខ្ញុំគិត ក្នុងចិត្តខ្ញុំថ៉ង អធិដ្ឋានផ្សង តាមបុណ្យបុពណា ៗ
ក្សិណនោះមហាក្សត្រ ព្រះបាទព្រហ្មទត្ត ធិពជថ្កើងថ្កាន ស្តាប់បុត្រ
បន្ទូល ក្រាបទូលក្សត្រក្សាន្ត ទើបព្រះអង្គមាន ព្រះបន្ទូលថា ៗ ហៃ
អស់អាមាត្យ ចូលទៅខ្ញុំឃាត ឆាប់-ឆាប់ម្និមា ស្រាលស្រីឲ្យបាន

មួយម្នាទរូបា មកឲ្យបុត្រា អញកាលនេះមុន ៗ អាមាត្យទូលថា ចៅយាយមាលា ល្អក្រៃកន្លង អស់អង្គឥន្ទ្រិយ ឥតបីមានខ្ពង លើសលែងស្រីផង លោកិយនេះនៃ ៗ បើព្រះរាជបុត្រ បានយល់ប្រាកដ សព្វព្រះដៀស្ដជ័យ មានព្រះទយា ស្នេហាពេកក្រៃ សព្វព្រះហឫទ័យ មិនទេឡើយណា ៗ ព្រះបាទឥសូរ ស្ដាប់អាមាត្យទូល ទើបព្រះរាជា ស្ដេចបើកព្រះសូរ បន្ទូលត្រាស់ថា ចៅយាយមាលា អាក្រក់ក្ដាត់ហោង ៗ គាត់ប្រាប់អញថា កើតព្យាធិរោគា ពេញតាំងខ្លួនហោង យកមកឥតការ អសារទេហោង នៃអស់គ្នាផង ព្រួយយើងទេណា ៗ អាមាត្យស្ដែងស្ដាប់ ស្ដេចបន្ទូលប្រាប់ ទើបក្រាបទូលថា បពិត្រព្រះបាទ ខរនាថករុណា យើងខ្ញុំអស់គ្នា ចង់ទៅឲ្យដល់ ៗ មើលឲ្យជាក់ជុំ មើលរូបឧត្ដម ពិសិទ្ធិមល យើងនាំមកថ្វាត់ ថ្វាយក្សត្រទសពល ទតឲ្យបានយល់ រូបនាងនោះណា ៗ ស្ដេចស្ដាប់អាមាត្យ ទូលទើបព្រះបាទ ត្រាស់បន្ទូលថា បើហ្នះចូរទៅ ចរទៅមើលពា ឲ្យសោះសង្កា សន្ទឹកសន្ទៃ ៗ ក្សិណនោះអាមាត្យ ក្រាបលាព្រះរាជ ក្សត្រាដៀស្ដជ័យ ទៅដល់គ្រឹហា យាយមាលានៃ ថ្លែងថាមាសថ្លៃ ព្រះបាទក្សត្រា ៗ ត្រាស់ប្រើយើងមក ប្រយោជន៍ទីង យក អង្គនាងឯណា ទៅឥឡូវថ្វាត់ មហាក្សត្រចេស្ដា ស្ដេចទឹងឲ្យជា មហេសីបុត្ររតន៍ ៗ នាងនាថស្ដែងស្ដាប់ អាមាត្យថ្លែងប្រាប់

ត្រេកអរពេកក្តាត់ គិតថាអញបាន រួមហ៊ានថេរបិត នឹងកូនអញ ពិត កាលម្ដងនេះនៃ ។ នាងនាថជាយា នឹងយាយមាលា ម៉ម្មា នៅ ទៅនឹងគាប់ ក្សត្រាជៀសួជ័យ កាលនោះឯងនៃ ពុំលង់ឡើយ ណា ។ ឪកម្មកផងយល់ នាងនាថមិល ទ្រង់តោមះសាកា សីង រត់មកមើល សរសើរថៃងថា នាងនេះល្អជា អស្ចារ្យពេកក្រៃ ។ នាងនាថជាយា ទៅផងគាប់ ក្សត្រាៈជៀសួជ័យ ដល់កដពេជរតន៍ ក្សត្រាថ្វាថ្វៃ ចតៈពញព្រះទ័យ ត្រេកសោមនស្ស ។ ក្សណមហា-ក្សត្រថ្វៃ ទ្រង់ព្រះក្រោធក្រៃ ជេរយាយមាលា មិនបោរកញ្ញាស់ កូត ណាស់មហិមា មិនប្រាប់អញថា ចៅអាក្រក់ក្រៃ ។ លុះអញឲ្យ យក បានចៅមិនមក ឥឡូវនេះនៃ នាងល្អកន្ទង់ ហាត់ហាង់ល្ហមល្ហៃ ឥតស្រើងវ៉ៃ ផ្ទឹមផងបានណា ។ ក្សណនោះព្រះចៅ ស្ដេចត្រាស់ ប្រើទៅ អញ្ជើញបុត្រា វរជកុមារ ត្រកាលម្ម៉ា មកថ្វាបិតា ពិពដ ជៀសួជ័យ ។ យល់ព្រះមាតា ស្ដេចពុំស្គាល់ជា ជននីក្សត្រថ្វៃ គិត ស្មានអ្នកព្រ្ដ ទាំងផ្ដាសវិស័យ សព្វព្រះហឫទ័យ កើតក្តួចស្នេហា ។ ចៅក្រឹស្នកុមារ ទូលព្រះភូបាល ព្រះវរបិតា សព្វព្រះហឫទ័យ ក្សត្រថ្វៃករុណា ខ្ញុំនឹងយកជា អយិអគ្គមហេសី ។ កាលនោះមហាក្សត្រ ព្រះបាទព្រហ្មទត្ត ស្ដាប់បុត្រក្លាប្រើយ ក្រាបទូលព្រះមហា ក្សត្រាធិបតី សម្ដេចភូមី ត្រេកសោមនស្ស ។ ស្ដេចឲ្យស្រីគ្ការ ព្រះ

ស្នំក្រមការ អករ៍យាយផងណា នាំនាងទៅស្រង់ ស្រេចទ្រង់គន្ធា
ចូងចន្ទន៍ក្រឹស្នា គ្រប់គ្រឿងប្រដាប់ ។ ស្ដេចឲ្យភ្នាក់ងារ រៀប
បណ្ណាការ បរិបូណ៌ស្រេចស្រាប់ ធ្វើការជាធំ ដោយក្រមក្រឹត្យច្បាប់
តិមង្គលគាប់ អាពាហ៍ពិពាហ៍ ។ អស់មុខមន្ត្រី សេនាបតី បុរោហិតា
រៀបពេនក្សត្រៃថ្ងៃ ច្រើនក្រៃណាស់ណា គាល់ព្រះរាជា ឆកជឧត្តម ។
អស់គ្រូឥន្ទ្រ៍ ពិណពាទ្យគើរ សោតសឹងប្រគំ បំរើក្សត្រា ដោយនា
ក្រឹត្យក្រម ច្បាប់ការជាធំ ឥតខ្ចះឡើយណា ។ ហើយគោះគងជ័យ
បុរោហិតសោតនៃ សឹងសូត្រគាថា ចំរើនសួស្ដី វិជ្ជ័យា ថ្វាយ
ពរព្រះមហា ក្សត្រទាំងពីរអង្គ ។ សម្ដេចភូបាល រៀបបណ្ណាការ បុត្រ
ទាំងពីរពង្ស ច្បាប់ការជាធំ ឧត្តមឧត្តុង្គ នៃទេពព្រះអង្គ ព្រះបាទ
ជេដ្ឋា ។ ស្ដេចយកបូរ៍ ចំរើនព្រះស្រី បុត្រពីរអង្គា ព្រះអង្គអភិ-
សេក ជាឯករាជា គ្រប់គ្រងសីមា ពារណសី ។ ស្រេចការហើយ
ណា ព្រះរាជបុត្រា ទូលព្រះជននី គង់ប្រាសាទមាស ទុះផ្ទាស់ស្មើ
ល្មះចូលរាត្រី យប់យូរសន្ធ្យា ។ ពន់វេលាកាល ទៅក្រស្នកុមារ
បរបរយាត្រា ទៅឋាននាងនាថ នាកាលនោះណា នៃទេពទេវត្តា
ចៃដន្យមកខ្ទី ។ កាលនោះមានឆ្មា មេនឹងកូនវា យល់ព្រះកូម
ស្ដេចយាត្រាទៅ សំដៅសិរសី កូនឆ្មាស្រដី ដណ្ដឹងមេវា ។
ថាហៃមេអើយ នរណាឯងហើយ ហៅបានមហិមា ដើរលើ

ក្បាលយើង ធ្ងន់ផងម្ល៉េះណា ពុំកោតសិរសា យើងដល់តិចឡើយ ។
រីឯមេធ្មា ថ្លែងឃាត់កូនថា អម្ចាស់កូនអើយ កុំកូនបារា ថ្លែងថាឈ្មោះ
ឡើយ លោកគោតគ្រូឡើយ យើងជាតិវេទ្ធន ។ អម្បាលទាត
បង្កើតសិរសា ម្ដេះកូនលោភហិន យកខ្លួយឯងជា ភរិយានៃប្រាណ
កុំកូនមាសមាន ចិត្តគិតចាះឡើយ ។ ក្សណៈនោះរាជា បានស្ដាប់
មេរ៉ា ស្រដីម្នោះហើយ ព្រះអង្គស្ដេចទាន់ ពុំបានទៅឡើយ ក្សត្រា
គ្រាណាត្រើយ ទៅផ្ទុំវិញណា ។ យាមមួយទៀតនោះ ស្ដេចរ៉េវ
ធ្លោះ គំរប់ពីគ្រា កាលនោះបារមេ ពពៃមួយណា បំពេះកូនរ៉
ពុំលង់ក្រ្តី ។ មេពពៃថា កូនអើយញាំងបា ដល់យល់ពោធិ៍ យក
ព្រះមាតា ឯងជាមហេសី ពុំដែលមានពិ- ឬកណាម្នេះណា ។
ក្សណៈនោះស្ដេចស្ដាប់ លុះឮសារសព្ទ ពាក្យពពៃថា ស្រដីម្នោះនៃ
ក្សត្រថ្ងៃយាត្រា ទៅផ្កានគ្រឡា បន្ទំវិញហោង ។ យាមមួយទៀត
ណា ស្ដេចទៅបូជា គំរប់ដង កាលនោះសោតនៃ សេះញីមួយ
ផង ទឹងកូនរ៉ហោង កូនសោតស្រដី ។ ដណ្ដឹងមេរ៉ ដូចកល់
ពាក្យធ្មា យើងបានថ្លែងពី កាលមុនជាអាទ៍ ព្រះបាទកុម្ពុល ក្រុសត្រ
ស្រដី ជាអស្ចារ្យក្រៃ ។ ស្ដេចទ្រង់ចិន្ដា ក្នុងព្រះទយា ថាអញនេះ
នៃ ព្រះវរបិតា ក្សត្រាជៀសជ័យ រើសអញពីព្រៃ មកជាកូនធម៌ ។
សមនាន់នេះណា ជាព្រះមាតា តែអញពុំស្គាល់ នេះសមទេត្ត

ធ្វើអស្ចារ្យស្រស់ ឲ្យអញបានយល់ ជាព្រះមាតា ។ សមអ្នកគ្រាប់
មក៏ ប្រយោជន៍នៅរក អញជាបុត្រា ដល់ស្រុកនេះអ្នក ពីងពាក់
នៅនា ផ្ទះយាយមាលា មែនមិនទេឡើយ ។ ស្ដេចទ្រង់ចិន្ដា
អម្បាលនូវប្រ-ការដូច្នោះហើយ ក្សិណនោះព្រះមហា ក្សត្រាត្រាណ
ត្រើយ ស្ដេចពុំលង់ឡើយ វិលវិញមកឋាន ។ ក្រឡាបខុំ ក្សិណ
ក្សត្រឧត្ដម ស្ដេចអធិដ្ឋាន ទីងអស់ព្រឹក្សា ទេវ្ដាហិមពាន្ត សោ·
ឲ្យសស្ដិហាន សីងសព្វប្រថពី ។ បពិត្រទេវ្ដា បើនាងនេះណា
ជាក់ជាជននី អញចរចូលទៅ ឥឡូវនេះទី សត្វឯងកុំបី ចរចាទៀត
ឡើយ ។ ស្ដេចអធិដ្ឋាន សច្ចាប្រណិធាន ជាស្រេចហើយ ក្សិណ
នោះព្រះអង្គ ពូជពង្សត្រាណត្រើយ ពុំធ្យរធ្យងឡើយ ស្ដេចទៅទៀត
ហោង ។ អស់សត្វនោះណា ពិតពុំចរចា ស្ងៀមស្ងាត់ជាម្ដង នៃ
ទើបព្រះមហា ក្សត្រាច្បាស់ច្បង់ ស្ដែងស្ដេចទៅផ្គង ដល់ព្រះមាតា ។
ឯព្រះជននី ប្រសើរសល់ស្រី យល់កដបុត្រា ទៅដល់ក្សត្រី ចុះពីគ្រ
ឡា បន្ទំមិម្មា ទៅឋានបុត្ររត់ ។ នាងបន្ទូលថា អ្នកឯងនេះណា
ព្រះបាទព្រហ្មទត្ត រើសអ្នកពីព្រៃ ហើយនៃមហាក្សត្រ យកអ្នកមក
ថ្នាក់ ជាកូនធម៌ថ្លៃ ។ អង្គអ្នកឯងណា ប្រាកដជាក់ជា កូនម្ដាយ
ឯងនៃ៖ កាលនោះម្ដាយព្រាត់ ខ្ចាយខ្ចាត់ចំពៃ ទីងអ្នកនៅនៃ ហិមពាន្ត
នាយ្ដណា ។ សម្ដេចភូមី ស្ដេចស្ដាប់ជននី ប្រាប់ព្រះពជា ទើប

ក្សត្រត្រកូល ស្តេចចូលមាតា ថាខ្ញុំនេះណា ផនកជៀសជ័យ ។
កាលនោះព្រះបាទ ស្តេចទៅប្រពាត រើសខ្ញុំពីព្រៃ យកមករក្សា
ជាកូនជមទៃ អង្គខ្ញុំសព្វថ្ងៃ ពុំស្គាល់ម្តាយឡើយ ។ ឯព្រះមាតា
ស្តាប់កូនទូលប្រ-ការដូច្នោះហើយ ទើបនាងថ្លែងថា ស៊ូនក្តាទាយអើយ
កុំកូនត្រាណត្រើយ សន្ធិះសង្កា ។ កូនអើយសំពត់ មួយដែលម្តាយ
បត់ ម្តាយក្រាលផ្តេកបា កាលម្តាយចូលឈប់ ក្រោមឫប់ក្រស្នា
ចិញ្ចៀនមួយជា ត្បូងសូរ្យកាន្តកែវ ។ សិងមានដំឡៃ ម្តាយចងទៅ
ដៃ កូនមាសប្រមាត់ ចិញ្ចៀននោះណា កក្រាទើបថ្វាត់ គង់នៅ
ឬបាត់ ណាកូនមាសថ្លៃ ។ សម្តេចកូម៉ី ស្តាប់ព្រះជននី ប្រាប់ដូច្នោះនៃ
ស្តេចជឿជាក់ជា មាតាក្សត្រថ្លៃ ឥតមានព្រះទ័យ សង្ស័សង្កា ។
ក្សណនោះព្រះអង្គ យកព្រះទំរង់ នូវព្រះពស្ត្រា ថ្វាយជាសាក្សី
ជននីកាលត្រា នោះឯងជាកប្រា-កដពិតពុំលង់ ។ សម្តេចកជា សែន
សោយសោកា ណាល់ណាសង្វេញទ្រង់ ក៏ខ្សឹកសោកសោះ កាល
នោះព្រះអង្គ ក្រាបក្រោមបាទប-ង្គ័ព្រះមាតា ។ ឯព្រះជននី វរពជក្សត្រី
ទទួលពស្ត្រា នូវព្រះទំរង់ កែវផ្គង់ហើយណា នាង់ឱបបុត្រា ទ្រង់
ព្រះកន្សែង ។ សែនសោយសោកា កាណ្ឌិតអនាថ បន្ទូលខ្ញុំថ្លែង
នូវកូនមាសថ្លៃ សព្វថ្ងៃម្តាយតែង ខ្សល់ខ្សត់ចម្បែង ក្នុងទ្រូងពីកូន

ជាទុក្ខមួយណា ផ្សៀតម្ដាយព្រាត់បា បុត្រស្ងួនក្ខាប្រិយ ទុក្ខមួយ
ផ្សិតព្រាស និពសស្វាមី សម្ដេចភូមី ជនកកូនអើយ ៗ ខេះ
ម្ដងម្ដាយបាន ហេតុបុណ្យបុរាណ ដូចនឹងបាហើយ កូនទ្រូង
ម្ដាយបាន ស្រាកស្រាន្តកូនអើយ ស្រយាលល្ហៃល្ហើយ ទុក្ខមួយនោះ
ហោង ៗ ចៅក្រឹស្នកុមារ កូនស្ងួនសង្សារ បង្គំទូលស្នង បពិត្រ
អ្នកម្ដាយ និយាយដើមទង ដំណាលទំនង ដំណើរនោះម្ដេច ៗ
នាងស្ដាប់បុត្រា ទូលសូមចិន្ដា ចង់ជ្រាបសាច់គ្រេប នាងចរចាចែង
ថ្វាថ្លែងសព្វសេច- ក្ដីប្រាប់សម្ដេច ព្រះរាជបុត្រា ៗ ឱ ! ម្ចាស់ម្ដាយ
អើយ ដំណើរដើមឡើយ ឯឪពុកបា គ្រប់គ្រងរេហ៍ពល សកល
យោធា ឋិតនៅសីមា ក្រុងទេពបុរី ៗ ឯអញម្ដាយបា ជាបុត្រក្សត្រា
ធិរាជធិបតី សោយរាជ្យនៅនា បញ្ចាលធានី ឯកឯងជាឥ- ស្សូរ
អស់រាស្ត្រផង ៗ ឯឪពុកបា គង់ហង្សយន្ដណា យាត្រាហោះផ្សង
ដូចដល់ស្រុកម្ដាយ ឯកាយជាម្ដង សំណាក់នៅផង ព្រាហ្មណ៍ប្រាជ្ញ
ហោក ៗ ហើយព្រះអង្គទៅ បំរើព្រះចៅ ជាជីតាបា ស្ដេចនៅ
ឯងអង្គ យូរលង់ទៅណា កាលនោះជីតា បាទ្រង់គ្រានក្រៃ ៗ ព្រះ
អង្គឡើងចាប់ នាំទៅសម្លាប់ នៅនាព្រះព្រៃ ឯតាពុកបា ប្រាជ្ញា
ឈ្មោងវៃ សម្ដេចជៀសជ័យ លួងអស់ពេជ្ឈឃាត ៗ ស្ដេចរួចពីភ័យ
គង់យន្ដមាសថៃ ហោះដល់ប្រាសាទ យកម្ដាយដាក់លើ ហង្សយន្ដ

មាសស្អាត ស្រេចហើយព្រះបាទ ហោះចេញមកវិញ ។ ចុះចំទីសំ-

ដៅ ទីនេះហោះផ្ទាះទៅ ក្រុងទេពបុរី ហោះពីសីមា បញ្ចូលជាទី

ចរចេញចាកពីរ ស្រុកប្រាំពីរថ្ងៃ ។ ពុំទាន់ដល់ឡើយ អម្ចាស់ម្ដាយ

អើយ គាប់ម្ដាយឈឺផ្ទៃ ទីទ្រង់ប្រសូត្របា ឯងណាមាសថ្លៃ ក្សិណ

ក្សត្រជៀសស្ដ័យ ព្រះជនកបា ។ កើបយន្តចុះឈប់ អាស្រ័យក្រោម

ម្លប់ ព្រះព្រៃសាខា ហើយម្ដាយសម្រាល បាកាលនោះណា កណ្ដាល

ព្រៃក្បា ហេមពាន្តព្រៃនោះ ។ ព្រះជនកបា យល់ម្ដាយរអ៊ា ស្ដេច

គង់យន្តហោះ ទៅរកអគ្គី ប្រាសពីកាលនោះ ទាសសូន្យសោះ

ទីម្ដាយហោងណា ។ កូនអើយម្ដាយនៅ នោះតាំព្រះបៅ ពីរនាក់

ទីងបា តាំបីទិនទាត់ យល់បាត់ឡោះណា ម្ដាយសោយសោកា

ណាស់ណាស់កូនអើយ ។ ម្ដាយយកព្រះករ ទាំងពីរម្ដាយគរ គកទុក

ហើយ ផលនេត្រស្រោក ឥតអាក់កូនអើយ មិនមានហៅ

សៀយ ពីទ្រូងម្ដាយណា ។ ម្ដាយសោកសន្ទប់ ឯកឯងសូន្យសព្វ

ដេកដោយឆាក ម្ដាយភ្ញាក់ស្មារតី ពីសន្ទប់ណា ហើយម្ដាយបីបា

រត់រកដោយព្រៃ ។ ម្ដាយឈប់ស្រែកហោ រកព្រះបមបៅ ពុំយល់

ឡើយនៃ កូនអើយម្ដាយអា- សូរបាបាលថ្ងៃ ម្ដាយឈប់អាស្រ័យ

ក្រោមដើមក្រស្នា ។ ម្ដាយយកសំពត់ នេះឯងម្ដាយបត់ ម្ដាយក្រាល

ផ្ដេកបា យកព្រះទំរង់ រតន៍ផ្ទង់នោះណា ម្ដាយបងដៃបា ហើយ

ម្ដាយផ្ដក់នៅ ៗ ក្រោមដើមក្រឹស្នា ម្ដាយចាំចៅបា ស្រេចហើយ
ម្ដាយទៅ រកព្រះជៀស្នដ័យ ដោយព្រៃជ្រោះជ្រៅ ពុំយល់ព្រះចៅ
ម្ដាយវិលមកថ្ងាត់ ៗ ដល់ដើមក្រឹស្នា ម្ដាយពុំយល់បា ស្មារតីម្ដាយ
បាត់ ដួលសន្ធប់នា ធាកហាំទស្ងាត់ ហេតុដ្បិតម្ដាយគាត់ ស្រ-
ឡាញ់កូនក្រៃ ៗ ម្ដាយសន្ធប់លង់ តែឯងឯកអង្គ កណ្ដាលទ្រូងព្រៃ
លុះភ្ញាក់ស្មារតី ម្ដាយពិលាបក្រៃ តាមកូនមាសថ្លៃ ដោយជាខនោះ
ណា ៗ ម្ដាយដើរព្រៃស្ងាត់ ឃើញតែហ្វូងសត្វ យេងយូងពាធា
ម្ដាយសោយសោកសល់ ទូញទល់ទុក្ខា ម្ដាយតាមរកបា ដល់ស្រុក
ខេះនៃ ៗ កូនអើយម្ដាយឈប់ ហើយម្ដាយជួនយប់ សូមបតគា-
ស្រ័យ ផ្ទះយាយមាលា គាត់ជាពេកក្រៃ ឃាត់ម្ដាយនៅនៃ នឹង
គាត់ហោងណា ៗ ហើយគាត់និយាយ ដំណើរប្រាប់ម្ដាយ ថាព្រះ
រាជា នាមព្រះព្រហ្មទត្ត មហាក្សត្រវិសេបា យកចិញ្ចឹមជា កូន
ធម៌ក្សត្រថ្លៃ ៗ ម្ដាយគិតចង់មក គាន់កូនពន្ធក ខ្ញាបក្សត្រជៀស្ន
ដ័យ ព្រះអង្គយកម្ដាយ មេមាយបេះនៃ ក្រែងមហាក្សត្រថ្លៃ យក
ជាមហេសី ៗ ម្ដាយនៅលង់ណា សោឡសវិស្សា ម្ដាយតែងក្រង
ភ្ញី ឲ្យយាយមាលា នាំផ្កាមកខ្ចី ថ្វាយព្រះភូមី នឹងបាឯងហោង ៗ
ក្រែងកូនមាសថ្លៃ បានយល់លាយដៃ ផ្កាដែលម្ដាយក្រង ហើយបាឲ្យ
យកៈ ម្ដាយមកជាបនិក្ខ បានជួបជូនផង កូនស្ងួនពុំស្គាល់ ៗ សម្ដេចភូមី

ស្តាប់ព្រះជននី បន្ទូលប្រាប់ប្រ. ការដូច្នោះនៃ ក្សត្រថ្ងៃសោភា បន្ទូល
ទួញថា ឱអម្ចាស់ថ្លៃ ៗ ម្តេចឡើយអ្នកម្តាយ លំបាកអំបាយ ពេក
ពន់ណាស់នៃ ប្រាសម្តេចទាំងកូន សោះសូន្យទីទៃ ប្រាសទាំង
ជៀសជ័យ ព្រះវរបិតា ៗ ឱព្រះជននី កាលកូនចាកពី ឲអ្នកណា
បានបីទិនចាត់ ហើយប្រាសព្រាត់គ្នា លង់លុះជួបជា សៅឡសន្នាំ
នៃ ៗ កំកូនពុំបាន ស្គាល់អ្នកមេមាន គុណគាប់ប្រពៃ ហេតុបាប
កូនឯង ពីព្រេងក្រាស់ក្រៃ ឲ្យប្រាសទីទៃ ឱឱព្រះមាតា ៗ កូន
ដូចតិរច្ឆាន សត្វជូសាមាន្យ មែនមិនស្គាល់ជា អ្នកមេមានគុណ
មហាធ្ងន់ឡើយណា នេះហេតុវេរ កម្មកូនឯងនៃ ៗ អ្នកស្គាល់កូន
ហើយ អម្ចាស់កូនអើយ ទើបតែនាថ្ងៃ នេះកូនស្គាល់អ្នក ជៀស
ជាក់ពេកក្រៃ ជននីនេះនៃ កូនសោយសោកសល់ ៗ កូនឃើញអ្នក
ហើយ អម្ចាស់កូនអើយ កូនជាទុក្ខទល់ គានគីងពក មួយប្រ.
ការគល់ ដ្បិតកូនពុំយល់ ព្រះវរបិតា ៗ អ្នកអើយកូនស្តាប់ ពាក្យ
អ្នកម្តាយប្រាប់ កូនរៃងឈើផ្កា ផ្កាយផ្សេងអស់អង្គ ប្រត្យង្គទយា
ដ្បិតកូនកំព្រា ប្រាសព្រះបមាទៅ ៗ ឱព្រះបិតា ធិកជឃ្លាតឃ្លា
ប្រាសពីកូនទៅ ជាព្រះអង្គមាន វិញ្ញាណសែនៅ ឬមួយព្រះចៅ
ក្សយក្សយជន្មា ៗ ឱព្រះទសពល កូនពុំបានយល់ ព្រះភក្ត្រអ្នកណា
ហេតុបាបកូនឯង ពីព្រេងដើរ ផ្តល់កូនក្រាលគ្រា នេះឯងកូនអើយ ៗ

ព្រះវរមាតា នាងស្តាប់បុត្រា សោយសោកពោះហើយ នាងនាថរែង
ជា សោកាតុំស្បើយ នាងថាកូនអើយ ម្តាយបាសព្វថ្ងៃ ។ នៅតែ
នឹងទុក្ខ ដៀតប្រាសអាពុក បាឃ្លាតទាំង ម្តាយឈឺផ្សាផ្សង សរេទ្រង
សង្រែ សន្ធឹកសង្វៃ ឥតស្បើយឡើយហោង ។ កូនអើយថ្ងៃបា ឲ្យ
សង់សាលា ឲ្យពានគោជន៍ផង ហើយគួរនិយាយ អភិប្រាយដើម
ទង ដំណើរទំនង កាលព្រាត់ប្រាសគ្នា ។ ក្រែងព្រះទសពល ស្តេច
ដើរមកដល់ ស្រុកនេះស្តេចជា អ្នកកំសត់បាន យកពានយើងណា
ហើយព្រះកជា ទតគំនូរផង ។ បើស្តេចទតយល់ សមសោយសោក
សល់ មិនទេឡើយហោង កូនអើយយើងបាន រួមឋានដូចបង ពាំង
បំជាម្តង ដូចចិត្តចិន្តា ។ កូនអើយមួយទៀត កុំបាស្រដី ប្រាប់ព្រះកជា
ថាជាម្តាយឡើយ កូនអើយថ្ងៃបា អភិប្រាយប្រាប់ថា ជាករិយាហោង។
ព្រះកជបុត្រា ស្តាប់ព្រះមាតា ក្សៀណក្សត្រប្បាស់ប្សង គាក់តែងប្រ-
ដាប់ ធាប់ធាប់ដូចបង ស្តេចត្រាស់ថាផង នឹងកូនភ្នាក់ងារ ។

បទពំនោល

កាលនោះចៅក្រឹស្នកុមារ ត្រាស់ប្រើអ្នកការ ប្រដាប់ឲ្យសង់
សាលា ដ្បិតស្តេចមានព្រះទយា ទ្រង់ព្រះសទ្ធា នឹងស្អាងព្រះកជកុ
សល ។ អាមាត្យបង្គំទសពល ទៅតែងខ្វាយខ្វល់ ប្រដាប់សង់ជាសា
លា ។ ជាងជាំងគ្នាក់ទៀតបនា ហានហានឲ្យជហ្វា កំស្អិនបំពមាស

ប្រាលផ្កៅ ៗ ស្រេចហើយអាមាត្យចូលទៅ ក្រាបទូលព្រះចៅ ក៏
ជ្រាបព្រះបាទកុបាល ៗ ក្បៀណនោះចៅក្រស្នកុមារ ឲ្យតែងក្នាក់ផ្ការ
មកគូរគំនូរប្រៃត ៗ មានជាងស្រាប់ស្រេចហើយនៃ ក្បៀណក្សត្រជៀស្ន
ជ័យ ខូរព្រះរាជមាតា ៗ ស្តែងស្តេចទៅដល់សាលា ទើបព្រះមាតា
បង្គាប់ឲ្យអស់ជាងផង ៗ គូរដោយដំណើរទំនង និយាយដើមទង
ព្រះបាទសម្តេចជេដ្ឋា ៗ ល្បែងមួយគូរកាលកជា គង់យន្តយាត្រា មក
ជាអាមាត្យក្សត្រថ្លៃ ៗ ព្រះចៅបញ្ចាលជៀស្នជ័យ ល្បែងមួយនោះនៃ
គូរកាលសម្តេចកជា ៗ ស្តេចទ្រង់ព្រះសុគន្ធា ជិតអស់អង្គា ក៏ប្រាល
រន្ទាលផ្កិនផ្កៅ ៗ ល្បែងមួយគូរកាលព្រះចៅ បញ្ចាលឲ្យហៅ ស្តេច
ទៅហើយទ្រង់គ្រោធា ៗ ឲ្យអស់ពេជ្ឈឃាតផងវា នាំព្រះកជា ទៅ
ដល់នាក្នុងព្រះព្រៃ ៗ ល្បែងមួយគូរកាលក្សត្រថ្លៃ គង់យន្តមាសមៃ
ហោះទៅដល់ប្រាសាទរតន៍ ៗ ល្បែងមួយគូរកាបេមហាក្សត្រ នាំនាង
នាថថ្វាត ហោះចេញពីឋាននោះណា ៗ ល្បែងមួយកាលកជា កើត
យន្តរេក កាលផ្តាំនៃព្រះជនក ៗ ល្បែងមួយគូរកាលកូមី កើតយន្ត
ហោះពី នោះទៅឈប់ក្រោមព្រះជ្រៃ ៗ នាងធ្នេរស្រះស្រង់នោះនៃ
ហើយក្សត្រថ្លៃ ប្រសូត្រព្រះរាជបុត្រា ៗ ហើយស្តេចជងព្រះគង្គា ស្រង់
រាជបុត្រា ស្រងទាំងព្រះអគ្គមហេសី ៗ ល្បែងមួយគូរកាលកូមី គង់
យន្តហោះពី កំឡុងព្រះជ្រៃនោះណា ៗ ទៅយកភ្លើងពីកេត្រា ល្បែង

មួយគូរជា នាងនាថទូវបុត្រាថ្ងៃ ។ នៅរង់ក្រោមដើមព្រះជ្រៃ ខាងវេឡរជល

ស័យ តែពីព្រះអង្គឯងហោង ។ នាងឲ្យគ្រូស្រេចហ្មត់ហ្មង ដោយបទទំ

នង ដំណើរដំណាលពកជា ។ នាងទតហើយសោយសោកា ទួញទៅ

រាជា ព្រះវៀមព្រះរាជស្វាមី ។ ព្រះរាជបុត្រាសិងពី- លាបផងជនទី

ទាំងពីរព្រះអង្គសោកា ។ លុះបន្ទូរសោកហើយណា នាងតែងភោជន៍

អា- ហារផងអនេកពេកក្រៃ ។ ឲ្យជាទានទិព្វប្រពៃ ស្វាមយាចកនៃ

ជាសព្វប្រក្រតីទៅណា ។ ហើយនាងនាថឲ្យទ្រព្យា នៃយាយមាលា

ឥតខ្វះកន្ទះឡើយហោង ។ ហើយឲ្យជាសេដ្ឋីផង ជាធំកន្ទង់ លែង

អ្នកទាំងឡាយនានា ។ ហើយនាងឲ្យចាំសាលា បើអ្នកឯងណា

ចូលមកយកទានយើងហោង ។ ឲ្យមើលអស់គំនូរផង ដោយបទទំនង

ដំណើរនិយាយនេះណា ។ ថាបើមើលហើយសោកា ចូរយាយម្នា

ទៅប្រាប់អញកុំលង់ឡើយ ។ នាងផ្តាំយាយមាលាហើយ ក្សណក្សត្រ

ត្រាណត្រើយ នូវរាជបុត្រាថ្លើមថ្លៃ ។ វិលថ្កានប្រាសាទមាសថៃ ព្រួយ

ព្រះហឫទ័យ អំពល់ទូរពោមខស្សា ។ ឯព្រះព្រហ្មទត្តរាជា ស្តេចពុំដឹង

ថា ជនខ្ចីនឹងបុត្រាឡើយ ។ ស្តេចថាជាភរិយាហើយ ក្សត្រាត្រាណ

ត្រើយ ស្តែងស្តេចសោមនស្សា ។ យើងថ្ងៃឯនាងបទុមា គេសរ

ទត្តម្យា ប៉ុនដួបនឹងរាជបុត្រា ។ យើងស្រែះទុកក្សណវិញណា ហើយយើង

ចរចា ឯនាយសំពៅមួយនៃ ៗ ដែលរើសហាងរួយទូមាសថៃ ចូលមក

ជួញៗ ខគពោធិណ្ណសីៈករ ៤ [illegible] (នៅមាំខត) [illegible]

# គតិបណ្ឌិតរបស់ព្រះបាទ ម៉ាក៏-អូរ៉ែល ព្រះអធិរាជរ៉ូម៉ាំង

លោក ភ៊យ-ពុក ដកស្រង់រៀបរៀង

---

១- ពេលក្រោកពីព្រឹក ចូរអ្នកនិយាយនឹងខ្លួនអ្នកថា "អញមុខជាជួបប្រទះនឹងមនុស្សដែលធ្វើឲ្យអញធុញទ្រាន់, មនុស្សអកតញ្ញូ, មនុស្សព្រហើនកោងកាច, មនុស្សពាលទុច្ចរិត, មនុស្សលោភលន់ពន់ប្រមាណ ដែលអញមិនចូលចិត្ត; បើជួបនឹងមនុស្សមានគុណវិបត្តិដូច្នេះ អញត្រូវគិតថា ព្រោះគ្នាមិនស្គាល់ល្អអាក្រក់" ។

២- គ្រប់តែម៉ោង, ចូរអ្នកព្យាយាមធ្វើនូវកិច្ចការទាំងឡាយដែលមានក្នុងបច្ចុប្បន្នយ៉ាងម៉ឺងម៉ាត់ ដោយចិត្តស្មោះស្ម័គ្រ ដោយរីករាយនឹងដោយយុត្តិធម៌ ។

៣- អ្នកកុំបំពេញសកម្មភាព ដោយមិនបានគិតជាមុន ។

៤- បើអ្នកធ្វើនូវកិច្ចការទាំងឡាយ ប្រកបដោយវិចារណញ្ញាណ ហើយ មិនបានលទ្ធផលដ៏ប្រសើរទេ ចូរអ្នកកុំស្អប់ខ្ពើម កុំលះបង់ព្យាយាម កុំលែងធ្វើកិច្ចការទាំងនោះឡើយ, បើអ្នកដួលហើយ ត្រូវតែក្រោកដើរទៅទៀត, ចូរអ្នកមានចិត្តរីករាយចុះ បើសកម្មភាពរបស់អ្នកមានសភាពថ្លៃថ្នូរគួរពេញចិត្ត ។

៥_ អ្នកអាចរស់នៅបានដោយសុខកាយសប្បាយចិត្ត ព្រោះអ្នកបេះត្រាច់ទៅតាមផ្លូវល្អហើយ, កិច្ចការទាំងឡាយអ្នកអាចបំពេញបាន

ទៅតាមមាត្រាច្បាប់ដែលគួរធ្វើ ។

៦- ចូរអ្នកយកចិត្តអ្នកទៅពិចារណាគន់វត្ថុទាំងឡាយ, ចំពោះវត្ថុមួយៗ ចូរអ្នកពិចារណានូវគុណសម្បត្តិនិងតម្លៃនៃវត្ថុនោះៗ ដោយម៉ត់ចត់ កុំឲ្យភាន់ច្រឡំ ។

៧- ចូរអ្នកលៃលកឲ្យបានស្រួលបួលចំពោះវត្ថុទាំងឡាយ ដែលមានជោគវាសនា ប្រកបដោយហេតុបច្ច័យទាក់ទង នឹងជោគវាសនារបស់អ្នក ។

៨- ចូរអ្នកស្រឡាញ់មនុស្ស ដែលស្ថិតនៅជុំវិញអ្នក តែការស្រឡាញ់នោះឲ្យមានសភាពស្មោះត្រង់ផង ។

៩- ចូរអ្នកទម្លាប់ផ្ទៀងត្រចៀកស្តាប់អ្នកដទៃនិយាយ ដោយការឆ្លិតឆ្លង់ ហើយចូរអ្នកតាមពិនិត្យមនោគតិរបស់អ្នកនិយាយ ។

១០- ចូរអ្នកក្រឡេកមើលខ្លួនអ្នក នេះជាប្រភពល្អ ហើយប្រភពល្អនេះ អាចនឹងបញ្ចេញទឹកមកបាន បើអ្នកចេះជីកកកាយជានិច្ច ។

១១- ជីវិតជាការតស៊ូ មិនមែនជារបាំទេ យើងត្រូវមានវិចារណញ្ញាណថា បើមានគេចូលមកច្បាំងដណ្តើមយើងដោយមិនដឹងខ្លួន យើងត្រូវក្រោកឈរតស៊ូនឹងគេដោយម៉ឺងម៉ាត់ ។

១២- បើអ្នកត្រូវការធ្វើកិច្ចការអ្វី ត្រូវអ្នកគិតគូរ ដេញដោលរកហេតុផលឲ្យជ្រៅឆ្ងាយសព្វគ្រប់ទៅក្នុងកិច្ចការទាំងនោះសិន ។

១៣- បើអ្នកបំបាត់ចោលនូវយោបល់របស់ខ្លួន ចំពោះកិច្ចការទាំងឡាយដែលនាំឲ្យវិនាស អ្នករមែងបានសេចក្ដីសុខជាភិយ្យោភាព ។

១៤- ចូរអ្នកទុកកំហុសរបស់បុគ្គលដទៃតាមុកខ្នងគេចុះ ។

១៥- ពិភពលោកមានការចលនាជានិរន្ដរ៍ ពីសតវត្សរ៍មួយទៅសតវត្សរ៍មួយ ។

១៦- វត្ថុដែលធម្មជាតិចែកមកឲ្យចំពោះជីវសត្វមួយៗ តែងមានប្រយោជន៍ដល់ជីវសត្វនោះៗ ។

១៧- អ្នកមិនត្រូវបង្ហាត់បង្រៀនបុគ្គលដទៃឲ្យអានសៀវភៅ ឬសរសេរ មុនខ្លួនឯងចេះអាន ឬសរសេរឡើយ ។

១៨- មនុស្សដែលកើតមកជាទាសាគេ គ្មានសំឡេងទេ ។

១៩- វត្ថុទាំងឡាយដែលអ្នកមានបំណងចង់បានក្នុងពេលអនាគត បើអ្នកចង់បានក្នុងថ្ងៃនេះ លុះត្រាតែខ្លួនអ្នកដាស់ត្រូវទឹងខ្លួនឯង ទើបបានសម្រេច ។

២០- ចូរអ្នកមើលដោយមំសចក្ខុនូវវត្ថុទាំងឡាយ ឲ្យឃើញថាមានសភាពយ៉ាងណាខ្លះ ហើយចូរបំបែកដោយបញ្ញាចក្ខុនូវវត្ថុនោះៗ តាមរូបលក្ខណៈទម្រង់ និងវត្ថុបំណងរបស់វាឲ្យច្បាស់លាស់ ។

២១- បើចង់ហាមឃាត់មនុស្សកាចកុំឲ្យប្រព្រឹត្តអាក្រក់ អ្នកត្រូវហាមកុំឲ្យដើមជ្រៃមានទឹកនៅក្នុងផ្ទៃជ្រៃ កុំឲ្យទារកយំ កុំឲ្យសេះស្រែកជាមុនៗ

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

(តមក)

លោក ភ័យ-ប៊ុក រៀបរៀង

ថ្ងៃមួយ លោកបានចូលទៅក្នុងព្រះវិហារក្នុងទីក្រុងមួយ បានប្រទះព្រះនាងកិស្ហីប៊ូជិន ជាជព្រះនាងក្វាន់នន ។ ព្រះនាងកិស្ហីប៊ូជិននេះ គេរចនាជារូបស្រីមួយយ៉ាងស្អាត ព្រះហស្តមួយដឹកដៃកូនក្មេង ព្រះហស្តមួយទៀតកាន់គ្រាប់បែក ។ ព្រះនាងជាបិសាច ត្រូវទណ្ឌកម្មក្នុងមួយថ្ងៃស៊ីកូនរបស់ខ្លួនមួយ ក្នុងបណ្ដាកូនតាំង ៥០០ ។ មានសេចក្ដីដំណាលថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់បានទេសនាទូន្មានព្រះនាងឲ្យឈប់ពីការស៊ីកូននោះ ដោយទ្រង់ព្រះរាជទានគ្រាប់បែក មានសភាពដូចដុំសាច់ឲ្យបរិភោគវិញ ។

ក្រៅពីនេះ លោកម៉ាត់ស៊ុដា មានសេចក្ដីពេញចិត្តចំពោះសាវករបស់ព្រះសម្ពុទ្ធមួយព្រះអង្គព្រះនាម ប៊ិនហ្សូរូ ។

មានសេចក្ដីដំណាលថា ព្រះសាវកប៊ិនហ្សូរូនេះ ជាអ្នកមានពន្លឺកាយទុព្វលភាព ជាអ្នកមានសំដីច្រើន, ដោយគុណវិបត្តិទាំងនេះបានជាពួកសាវកដូចគ្នា បានបណ្ដេញចេញពីគណៈសង្ឃ ។ ព្រោះហេតុនោះ បានជាគេរចនារូបរបស់លោកដំកល់នៅខាងក្រៅបូជនីយដ្ឋាន

គឺមុខទ្វារព្រះវិហារ ។ ប៉ុន្តែ ព្រះសារីរិកអង្គនេះ មានគុណវិសេសមួយទៀត គួរឲ្យពេញចិត្តពន់ពេក គឺលោកអាចធ្វើរោគាពាធឲ្យសះស្បើយបាន ។ ពួកជនខ្លះ បានយកកន្លែងឈឺរបស់ខ្លួនទៅជជុសចុះឡើងលើព្រះរូបនោះ, លុះជម្ងឺរបស់ខ្លួនជាសះស្បើយហើយ អ្នកខ្លះថ្វាយគ្រឿងបូជាៈដោយដេរម្លូកបំពាក់ ខ្លះយកកំណាត់ព្រែ ធ្វើជាលំអព្រះស្ពង់ ។ ព្រោះហេតុនោះ នៅខ្លោងទ្វារព្រះវិហារ, ព្រះរូបប៊ិនហ្សូរូតែងមានវត្ថុផ្សេង ៗ ជាគ្រឿងបូជា ដោយគ្រួសារនីមួយ ៗ យកមកពាក់-តែងលំអគួរឲ្យសើច តែគួរឲ្យមានសមានចិត្តចំពោះគុណវិសេសនៃព្រះរូបនោះដែរ ។

លោកម៉ាត់ស៊ីដា លោកមិនបានគោរពបូជា ព្រះប៊ិនហ្សូរូនេះទេ លោកតែងគោរពរាប់អានព្រះជីហ្សូវិញ ។

ព្រះជីហ្សូជាមិត្តរបស់កូនក្មេង ជួយដកចេញក្មេងដែលឈឺ ។ កាលណា ទារកយំនៅក្នុងផ្ទះម្នាក់ឯង, ព្រះជីហ្សូតែងមកលួងលោមបញ្ចាសអន្ទើលក្មេងនោះ ។ មួយទៀត ព្រះជីហ្សូជាអ្នកជួយបំពេញកិច្ចចំពោះក្មេងដែលទទួលមរណភាព, កាលបើមាតាបិតាក្មេងនោះព្រួយចិត្ត ដោយកូនខ្លួនទទួលមរណភាពដូច្នោះ ហើយបោះបង់ចោលការងារទាំងឡាយ បែរតែទៅយំកន្ទក់កន្ទេញនៅក្បែរផ្នូរនោះ ។ ព្រះអាទិទេពនឹងដាក់ទណ្ឌកម្មចំពោះកូននោះ តម្រូវឲ្យជញ្ជូនថ្ម មកគរទុកនៅក្បែរមាត់ទន្លេមួយ

នៃស្ថាននរក ។ ព្រះឯដីហ្សូនេះ ទៅជួយជញ្ជូនដុំថ្មក្មេងដោយសេចក្តីអនុគ្រោះ ។ ដូច្នោះ មាតាបិតារបស់ក្មេងទទួលមរណភាព, ដើម្បីនឹងបន្ធូរបន្ថយសេចក្តីសោកស្តាយរបស់ខ្លួន ក៏ជញ្ជូនដុំថ្មយកមកដាក់ចំពោះព្រះភក្ត្រព្រះដីហ្សូ ជាគ្រឿងតបស្នង ។

លោកម៉ាត់ស៊ូដា លោកមានចិត្តទោរទន់ ហើយលោកពេញចិត្តក្នុងការគោរពរាប់អានព្រះដីហ្សូនេះបំផុត ។

រូបព្រះដីហ្សូនេះ មានទ្រង់ទ្រាយជាព្រះសង្ឃ ព្រះកេសកោររលីង ព្រះភក្ត្រញញឹម ព្រះហស្តម្ខាងកាន់គ្រឿងអលង្ការ ព្រះហស្តម្ខាងទៀតកាន់ដំបង ។

ថ្ងៃមួយ លោកបានអញ្ជើញទៅកាន់ទីក្រុងមួយ ដើម្បីទិញរូបព្រះដីហ្សូធ្វើពីថ្ម លុះចូលទៅដល់ទីក្រុង ក៏ចូលទៅកាន់ផ្ទះពាណិជម្នាក់ដែលលក់រូបចម្លាក់ឈ្មោះ តាកឹហ្សាវ៉ា ហើយឲ្យពាណិជនោះធ្វើរូបព្រះដីហ្សូចំនួន ៦ អង្គ ។ នាយពាណិជបានធ្វើកិច្ចសន្យាជាមួយលោកម៉ាត់ស៊ូដាថា នឹងចាត់ឲ្យជាងចម្លាក់ម្នាក់ធ្វើរូបព្រះដីហ្សូ៦អង្គនោះ ឲ្យបានក្នុងរវាង ២ ខែ ។

មុននឹងយកហិបទៅដាក់រូបព្រះដីហ្សូនោះមួយថ្ងៃ, លោកម៉ាត់ស៊ូដាមានបំណងចង់ឃើញរូបនោះយ៉ាងក្រៃលែង លោកក៏អញ្ជើញទៅកាន់ផ្ទះលោក តាកឹហ្សាវ៉ា ។ ខណៈនោះ លោកតាកឹហ្សាវ៉ា

មិនទាន់យករូបព្រះជីហ្សូទាំង ៦ នោះមកដល់ផ្ទះនៅឡើយទេ លោក
មានចិត្តញ្ញាកមិនចង់ជំរាបសេចក្ដីពិតទៅលោកម៉ាត់ស៊ុដាសោះ ដោយ
ហេតុយល់ថា ក្រែងលោកម៉ាត់ស៊ុដាអាក់អន់ចិត្ត ព្រោះលោកអញ្ជើញ
មកពីខែត្រឆ្ងាយបំណងឃើញព្រះជីហ្សូទាំង ៦ នោះណាស់ ៗ លោក
តាគីហ្សាកាំពិចារណាក្នុងចិត្តដើម្បីនឹងរកមធ្យោបាយផ្សេងៗ សម្រួលដល់
ផ្ទះនេះ ឲ្យបានសម្រេចដូចបំណង, ក្នុងមួយរំពេចនោះ ចំពើម
លោកញាក់ព្រើតៗ លោកក៏សើចញញឹមដោយយល់ថា ក្នុករបស់
លោកម៉ាត់ស៊ុដានឹងមើលមិនសូវច្បាស់ ៗ ម្យ៉ាងទៀតលោកតាគីហ្សាកាំ
មានមិត្រម្នាក់ នឹងមនុស្សជំនួយពីនាក់ លោកក៏បង្គាប់មនុស្សទាំង ៣
នេះឲ្យក្លែងខ្លួនធ្វើជារូបព្រះជីហ្សូ គឺយកស្បង់ចីពរលោកសង្ឃមកគ្រង
ឲ្យ ដៃម្នាក់កាន់គ្រឿងអលង្ការ ដៃម្នាក់ទៀតកាន់ដំបង ហើយបង្គាប់
អ្នកទាំង ៣ ថា បើកាលណាលោកម៉ាត់ស៊ុដាអញ្ជើញមកមើល ត្រូវ
កុំសើច កុំកំរើកដៃជើងឲ្យសោះ ៗ លោកតាគីហ្សាកាំ លុះរៀប
ចំយ៉ាងនេះរួចហើយ ក៏និយាយនឹងលោកម៉ាត់ស៊ុដាថា ខ្ញុំនឹងបង្ហាញនូវ
រូបព្រះជីហ្សូ ៣ ព្រះអង្គសិន រួចហើយទទួលទានទឹកតែ តទៅយើង
នឹងមើលព្រះរូបព្រះជីហ្សូ ៣ ទៀត ដែលនៅបន្ទប់ផ្សេងគ្នា ៗ

លោកតាគីហ្សាកាំ ក៏នាំលោកម៉ាត់ស៊ុដាទៅទស្សនារូបព្រះជីហ្សូ
ដែលដំកល់ទៅក្នុងបន្ទប់ជិតនោះ ៗ ចំពោះព្រះរូបមួយៗ លោកបាន

ឱនក្បាលគោរពយ៉ាងស្មោះចំពោះ ហើយសូត្រធម៌ផង លោកពិនិត្យដោយការហ្មត់ចត់ណាប់ បានបញ្ចេញពាក្យសរសើរយ៉ាងក្រៃលែងចំពោះរូបព្រះជីហ្សូទាំង ៦ នោះ ។

ដោយហេតុតែលោកមានសេចក្ដីពេញចិត្ត ចំពោះរូបព្រះជីហ្សូនោះពន់ពេក ទើបលោកមិនទាន់អញ្ជើញទៅកាន់គេហដ្ឋានវិញទេ . . . តើលោករង់ចាំអ្វីទៀត . . . , គ្រានោះ លោកម៉ាត់ស៊ុដា ក៏ពោលទៅកាន់លោកតាគីហ្គុកថា ខ្ញុំចង់ឃើញរូបព្រះជីហ្សូទាំងប្រាំមួយជាមួយគ្នាបានឬទេ ? ដើម្បីនឹងប្រៀបធៀបគ្នា ។

បានជាលោកម៉ាត់ស៊ីដា ចង់ឃើញរូបព្រះជីហ្សូក្នុងពេលជាមួយគ្នាដូច្នោះ មកពីលោកសង្កេតឃើញព្រះជីហ្សូមួយៈនោះញញឹម . . . នឹងព្រះជីហ្សូមួយទៀត បានបញ្ចេញសំណើចញូរស្រាល មិនសូវច្បាស់ . . . ។

ឯនាយពាណិជ្ជករ៍អេះក្បាល ហើយនិយាយទៅកាន់លោកម៉ាត់-ស៊ីដាថា បន្ទប់ផ្ទះរបស់ខ្ញុំតូចពេក មិនអាចនឹងនាំយករូបព្រះជីហ្សូទាំង ៦ ដាក់ឲ្យសណ្ដិតជាជួរជាមួយគ្នាបាន , ដូច្នោះ ខ្ញុំនឹងនាំលោកទៅទស្សនាក្នុងបន្ទប់មួយទៀត ដែលមានព្រះជីហ្សូ ៣ អង្គនៅក្នុងនោះ ។

លោកម៉ាត់ស៊ីដាយល់ព្រម ក៏អញ្ជើញចូលទៅក្នុងបន្ទប់មួយទៀត,

តែមានសត្វស្វាបែបចម្លែក ដែលនាំឲ្យលោកបែរមុខត្រឡប់ទៅក្រោយ មួយរំពេចនោះ " តើលោកបានឃើញអ្វី ? . . . ។

ព្រះរូបដ៏ល្អដែលតាំងជាជួរនៅកន្លងមុខនោះ បានរត់ចេញដោយធាប់ហើសពីទីកន្លែង . . . ។

លោកម៉ាត់ស៊ីជា ពិតមែនតែពពកមានភ្នែកងងឹតមើលមិនសូវច្បាស់ ប៉ុន្តែ លោកសំគាល់ប្រហាក់ប្រហែលថា ដូចជាព្រះរូបនោះចេះដើរទៅ . . . ឬជាសភាពពិតមែន ឬយ៉ាងណាមិនទាន់ប្រាកដ . . . ។

គន់ពេលដែលគិតលោកម៉ាត់ស៊ីជាកំពុងរំជួលខ្លាំង ពេលនោះលោកបានងាកត្រឡប់ទៅក្រោយ , ស្រាប់តែព្រះដ៏ល្អ ១ អង្គរត់មកប៉ះកែងដៃរបស់លោក តែមិនមែនព្រះរូបទេ ជាមនុស្សមានសាច់ឈាមទ្រង់ទ្រាយជាមនុស្សជាតិពិត ៗ ។ លោកម៉ាត់ស៊ីជា ក៏យល់ច្បាស់ដោយបញ្ចាក់ថា ពាណិជ្ជការីហ្វាក់ប៉ាកបញ្ឆោតលោកពិតប្រាកដណាស់ ចិត្តរបស់លោកក្តៅក្រហាយជាខ្លាំង ដោយលោកគិតឃើញថា មិនសមបើលោកតាការីហ្វាក់ ហ៊ានបោកបញ្ឆោតមនុស្សស្លូតត្រង់មិនកោតញញើតសោះ សំគាល់ឯងជាមនុស្សមានភ្នែកខ្វាក់ ឥតមានសទ្ធាជ្រះថ្លាកន្លងព្រះពុទ្ធសាសនា ។

ប៉ុន្តែ លោកម៉ាត់ស៊ីជា ទប់កំហឹងនោះបាន ដោយលោកនឹក

ដល់ព្រះពុទ្ធោវាទថា "ត្រូវបំបាត់សេចក្ដីក្រោធ ដោយមិនក្រោធ" ។

លោកម៉ាត់ស៊ីដា ក៏អត់ទោសឲ្យលោកតាកីហ្សាភ៏ក្នុងពេលនោះ ។

ចប់រឿងព្រះដីហ្សូតាំង ៦ ។

## ៣–រឿងបិសាចលោកសង្ឃ

ណមោ អមិតា ប៊ុតស៊ឹ! ណមោ អមិតា ប៊ុតស៊ឹ! ខ្ញុំសូមគោរពព្រះសម្មាសម្ពុទ្ធជាម្ចាស់ ! ។

មានសេចក្ដីដំណាលថា មានលោកសង្ឃមួយអង្គ សូត្រធម៌តាមប្រពៃណីឈរនៅមុខគោជទីយដ្ឋាន ១ ជិតទីក្រុងណាគូយ៉ា ។ លោកបានឈប់នៅទីនោះ ដើម្បីនឹងសូមបច្ច័យបិណ្ឌបាត ។ តែគ្មានអ្នកណាម្នាក់អើពើនឹងព្រះសង្ឃនេះសោះឡើយ ។ លោកបានរង់ចាំដោយសេចក្ដីស្ងប់ស្ងៀម គ្មានកំរើកព្រះអង្គសោះ ។

លោកសង្ឃនេះ រាងតូចស្ដើង ព្រះកេសកោរ ព្រះភក្ត្រពណ៌លឿងស្គមហើយញញឹម ព្រះទ័យពេញទៅដោយអចលស្រទ្ធា ចំពោះព្រះពុទ្ធសាសនាយ៉ាងក្រៃលែង ។

នៅជិតលោក, មានបុរសអនាថាម្នាក់ដែលជាមនុស្សឥតទីពំនាក់ តែងត្រាច់ទៅតាមនិគមជនបទ ក្នុងប្រទេសជប៉ុនទាំងមូល ។ បុរសនេះមានមាឌធំ ស្គម សាច់លឿង ស្បែកជ្រួញជ្រីវ ។ តែបើសង្កេតមើលបុរសនេះដោយជាក់ច្បាស់ទៅ មិនមែនជាមនុស្សព្រើសខាងកម្មដ្ឋានទេ ។

ហេតុដែលធ្វើឲ្យបុរសមានលក្ខណៈយ៉ាងនេះ មកពីការលំបាកតោក យ៉ាកអត់ឃ្លាននេះឯងជាដើមហេតុ ដែលបានបោទុកស្នាមលើផ្ទាសមុខ មាត់គាត់ ។ បុរសអនាថានេះ មកកាន់គោដនីយដ្ឋានដើម្បីសុំអាហារ បរិភោគ ។ ដល់មិនឃើញអ្នកណាមកសួរ, បុរសនេះក៏ទះដៃខ្លួន ដើម្បីស្រែកហៅនាងតាសីម្នាក់ដែលឈរនៅទីនោះ ។ តាសីនោះ ក៏ ដើរចូលមក តែនាងមានសេចក្តីញញើតញញើម ព្រោះមិនដឹងជាបំរើ អ្នកណា បំរើលោកសង្ឃ ឬគ្រហស្ថ ។

ឯលោកសង្ឃនោះ មានពុទ្ធដីកាថា ចូរនាងបំរើបុរសនេះ ដែល ជាមេយោធាចុះ ព្រោះគាត់អញ្ជើញមកកាន់ទីនេះមុនអាត្មា ប្រហែល ជាគាត់ប្រញាប់ទៅកាន់ទីដទៃទៀត ។

បុរសនោះតបទៅវិញថា ទេ! ចូរនាងបំរើព្រះសង្ឃមុនខ្ញុំចុះ ព្រោះ ព្រះសង្ឃជាបុរសពិសិដ្ឋគួរគោរពបូជា ទាំងជាបុគ្គលមានកិត្តិយស ។

អ្នកទាំងពីរពោលធ្វើយឆ្លងគ្នាទៅវិញទៅមកដោយបោរាគព ។

បុរសក៏ពិតតុទ្ធដីកាព្រះសង្ឃថា ខ្ញុំឈ្មោះ តាជិមាស្ហូម (Tajima Shume) ។

ចំណែកនាងតាសី ក៏ពាត់ថែនយកបាយលាយទៅដោយទំពាំងទីង ក្រុងឈ្ងុក មកប្រគេនព្រះសង្ឃពាទនឹងជូនបុរសពិសា ។ អ្នកទាំងពីរក៏ សាកសួរគ្នាទៅវិញទៅមក ទើបដឹងថា បំណងនិមន្តទីងដើរទៅកាន់ក្រុង

គីយ៉ូតូ (Kyôto) តាមផ្លូវមាត់សមុទ្រខាងកើត, គេឲ្យឈ្មោះទីក្រុងនេះ ថា តូកៃដូ ។

លោកសង្ឃនិងបុរស ក៏ចេះតែត្រាច់ទៅជាមួយគ្នា, នៅ៥៣ រយៈផ្លូវទៀតទើបដល់ទីក្រុងគីយ៉ូតូ ។

អ្នកទាំងពីរគ្មានវត្ថុអ្វីជូនទៅជាមួយទេ, បុរសមានតែដាវសាម៉ូរៃ ២, ឯលោកសង្ឃមានកាន់កញ្ចប់តូចមួយរុំនឹងកូនកន្សែងពណ៌លឿង ។

លោកសង្ឃនិមន្តបណ្ដើរជជែកជាមួយបុរសនោះបណ្ដើរ លោកមានពុទ្ធដីកាអំពីទស្សនីយភាពនៃសត្វលោកទាំងមូល, ឯតាជម៉ាស្ហុម បានពណ៌នាអំពីជីវភាព ហើយចេះនិយាយពីរឿងនេះរឿងនោះយ៉ាងក្បោះក្បាយគួរឲ្យចង់ស្ដាប់ពន់ពេក ។ នៅតាមផ្លូវ, មានទេសភាពគួរឲ្យពិតពិលរមិលមើលគឺ: មានព្រះសង្ឃនិមន្តតាមថ្នល់ គ្រហស្ថត្រាច់តាមក្រោយ, មានពួកបួជនីយេសក៍ ដើរត្រសងទៅកាន់ព្រះវិហារ ដែលឋិតនៅទីក្រុងតូកៃដូ, មានអ្នករប្រៀង, អ្នកថ្លែងរឿងព្រេង ស្ទូមយាចកជាច្រើន ត្រាច់ទៅមកមិនដាច់ . - ។ ហួសពីនេះបន្តិចទៅ ឃើញពួកព្រះអ្នកម្ចាស់ ភាសាជប៉ុនហៅថា ដៃម៉ីយ៉ូ (Daimyô) ទ្រង់ព្រះពស្ត្រព្រះភូសាជាកិត្តិយស គង់លើព្រះទីនាំង អស្សរេ ឬវមាស, មានពួកយោធាសាម៉ូរៃដើរអមសងខាង ។ កាលបើព្រះអង្គម្ចាស់ស្ដេចយាងទៅដល់ទីណា, ទីនោះ តែងមានពួកពលរដ្ឋធ្វើគារវកិច្ច គំនុំក្បាល

ទង្គិចដី ។ គពីនេះមានពួកករីកំពុងដើរទស្សនាទូរទីជ្រើវ ទីងពួក
ជាងគំនូរកំពុងគូររូបភាពជាច្រើន ។

(សព្វថ្ងៃ ថ្នល់ពីកដជាទីតួក្យទៅកាន់ទីក្រុងតីយ៉ូតូ ចម្ងាយប្រាំយ
គីឡូម៉ែត្រ មានក្រាលថ្ម ចាក់កៅស៊ូ ដាំដើមស្រល់ ទីងដើមសែដ្រ
( Cèdres ) តាមមាត់ថ្នល់ . . ) ។

ថ្ងៃមួយតមក លោកតាជម៉ាស្តុម កំផ្តើមនិតានរឿងរ៉ាវកាលពីអតីត
កាលរបស់ខ្លួនពិតពុទ្ធដីកាចំពោះព្រះសង្ឃនោះ ។ ឯព្រះសង្ឃឥតបាន
ដឹងថា សកម្មភាពដែលបុរសនោះបំពេញក្នុងការធ្វើសង្គ្រាម ឬសម្លាប់
មនុស្សទេ ។ ប៉ុន្តែ លោកតែងមានពុទ្ធដីកាថា យើងមិនត្រូវប្រហារ
ជីវិតសត្វដទៃឬធ្វើទារុណកម្មចំពោះមនុស្សជាតិទេ បុគ្គលទីមួយៗ រមែង
ប្រព្រឹត្តទៅតាមជោគវាសនាសព្វ ។ ខ្លួន ក្រោយដែលខ្លួនធ្វើមរណកាល
បុគ្គលខ្លះ ក៏ត្រឡប់មកចាប់បដិសន្ធិជាសត្វតិរច្ឆាន ខ្លះទៀតជាមនុស្ស
បុគ្គលទីមួយ ។ ត្រូវកើតស្លាប់ ។ វិលវល់នៅក្នុងវដ្តសង្សារជាច្រើនជាតិ
បើគេព្យាយាមកសាងខ្លួននៅក្នុងអំពើជាកុសល គេនឹងចិតចូលទៅជិត
ព្រះនិព្វានដែលជាទីរំលត់បង់នូវសង្សារវដ្ត, កាលបើដូច្នេះសត្វលោក
ទាំងអស់ រមែងចូលទៅកាន់ព្រះនិព្វានដូចជាព្រះសម្មាសម្ពុទ្ធដូច្នោះ ។
ព្រះសង្ឃនេះ មានពុទ្ធដីកាបណ្តើរ សូត្រធម៌បណ្តើរថា ណមោ
អមិតា ប៊ុតស៊ូ! ណមោ អមិតា ប៊ុតស៊ូ! ហើយលោក

បានបញ្ចេញនូវសេចក្តីសង្ស័យរបស់លោក ចំពោះអនាគតនៃព្រះពុទ្ធសា-សនាឲ្យតាជម៉ាស្ហុមស្តាប់ ព្រោះលោកដឹងថា បុរសតាជម៉ាស្ហុមមានៈ សន្តានចិត្តស្លូតបូតគួរសម មិនដែលពោលរាំចាផ្ទុយនឹងលោកឡើយ ។

ការដែលជួបគ្នាក្នុងរយៈវេលា ២–៣ ថ្ងៃ ប៉ុណ្ណោះ ធ្វើឲ្យអ្នកទាំងពីរទៅជាមិត្រភក្តិនឹងគ្នាយ៉ាងជិតស្និទ្ធ មិនមានការលាក់គំនិតរវាងគ្នានឹងគ្នាឡើយ ។

ចំណែកព្រះសង្ឃលោកមានពុទ្ធដីកាដោយព្រះទ័យស្មោះត្រង់ថា លោកជ្រះបទេ ! ក្នុងកញ្ចប់ដែលអាត្មាកាន់នៅដៃនេះតើមានអ្វី ? ។

បុរសនោះ ពោលតបថា ខ្ញុំព្រះករុណាមិនដឹងទេ, ហើយបុរសនេះ ត្រឡប់សួរព្រះសង្ឃវិញថា របស់មានសារៈសំខាន់ឬ ? ។

ព្រះសង្ឃមានពុទ្ធដីកាថា កញ្ចប់នេះ មានសារៈសំខាន់ណាស់ ។

បុរសពិតពុទ្ធដីកាថា ប្រហែលជាខ្សែគ្រាំ ដែលលោកម្ចាស់បានខ្ចប់ នៅពេលដែលនិមន្តទៅកាន់បូជនីយដ្ឋានទេដឹង ! ។

– មិនមែន !

– ប្រហែលជាសៀវភៅដែលមានពុទ្ធភាសិតយ៉ាងពីរោះផ្អែមល្ហែមសំរាប់មានពុទ្ធដីកាទៅកាន់មនុស្សទូទៅឬ ? ។

– មិនមែនសោះឡើយ ។

បុរសនេះ តែងគិតមកក្នុងចិត្តថា ប្រហែលជាព្រះចង្កូមកែវ

ព្រះសម្មាសម្ពុទ្ធទេដឹង ។ តែបុរសនោះមិនហ៊ានសួរ បិតនៅស្ងៀមស្ងាត់ ឥតពោលអ្វីតទៅទៀត ។

ចំណែកព្រះសង្ឃនោះ ពោលបន្ថែមទៀតថា នៅក្នុងកញ្ចប់នេះ មានប្រាក់ ២០០ ដំឡឹង ។

បុរសនោះ ស្ងើចយ៉ាងខ្លាំង ហើយពោលថា ព្រះតេជព្រះគុណ មានព្រះពុទ្ធដីកាលេងទេដឹង , បើព្រះតេជព្រះគុណ មានប្រាក់ដល់ចំនួនប៉ុណ្ណោះ មិនមែនត្រាច់រង្គាត់តាមផ្លូវដូច្នេះ ប្រាកដជាគ្រងចីពរល្អជាងនេះ ហើយមិនមែននៅសិងតាមភោជនាគារ ដ៏ខ្សត់ទ្រព្យដូច្នេះទេ ប្រហែលជាហៅឲ្យព្រះករុណាទៅបរិភោគអាហារនៅភោជនាគារដ៏ថើតឆាយពុំខាន ។

ព្រះសង្ឃក៏គាន់តែកំផ្លែងតទៅទៀតថា : ទេ ! អាត្មាមិននិយាយលេងទេ អាត្មាមានប្រាក់ ២០០ ដំឡឹងពិតមែន , តែប្រាក់នេះ មិនមែនសម្រាប់យកមកចាយវាយជាប្រយោជន៍ផ្ទាល់ខ្លួនអាត្មាទេ, បើលោកចង់ដឹងការស្ងាត់កំបាំងរបស់អាត្មា, គួរលោកចាំស្តាប់ អាត្មានឹងពណ៌នាអំពីរឿងនេះ ៖

ថ្ងៃមួយ អាត្មាបានដើរទៅកាន់ក្រុង អូប៊ី ហើយចូលទៅក្នុងព្រះវិហារឈ្មោះអ៊ីគីតាមី ប្រហែលជាលោកធ្លាប់ស្គាល់ទីនោះដែរ ។ បុរសនោះ ក៏បញ្ចេញកាយវិការជាសញ្ញាថា ខ្លួនធ្លាប់ស្គាល់ដែរ ។ ពេល

នោះ ជាពេលដែលមានធម្មជាតិទាំងឡាយស្រស់បំព្រង គឺមានមេឃស្រឡះ ស្ទឹក-ផ្កាឈើស្រស់ល្អ ។ ក្នុងពេលមួយរំពេចនោះ នៅនាព្រះវិហារអឺគីតាម៉ី គេបានវាយជួងប្រមូលភិក្ខុសង្ឃនិងគ្រហស្ថឲ្យចូលទៅក្នុងព្រះវិហារ ដើម្បីធ្វើសមាធិនិងសូត្រធម៌, ពេលនោះ អាត្មាក៏បានចូលទៅដែរ ស្រាប់តែមានបីតិសោមនស្សកើតឡើងក្នុងចិត្តរបស់អាត្មាចំពោះព្រះសម្មាសម្ពុទ្ធ ហើយបានប្តេជ្ញាក្នុងចិត្តថា « ក្នុងមួយជីវិតនេះនឹងព្យាយាមកសាងព្រះពុទ្ធរូប ១ ព្រះអង្គធ្វើពីសំរិទ្ធយ៉ាងល្អប្លែក" , បន្ទាប់ពីនោះមក អាត្មាក៏ខំដើរឃោសនាបច្ច័យគ្រប់ក្រុង ខេត្ត ស្រុកក្នុងប្រទេសជប៉ុននេះ, ពេលនេះ អាត្មាប្រុងទៅរកខេត្តក្រុងតូយ៉ូតូ រកជាងចម្លាក់ម្នាក់ ដើម្បីសម្រេចវត្ថុបំណងរបស់អាត្មា ។

ពេលនោះ ព្រះថេរដ៏តូចនៃព្រះសង្ឃនោះ ក៏បញ្ចេញនូវអាការៈជាសញ្ញាឲ្យដឹងថា លោកមានព្រះទ័យជាប់ស្អិតចំពោះការរចនាព្រះពុទ្ធរូបនោះ ហើយព្រះសង្ឃនេះ ក៏មានពុទ្ធដីកាទៅតាមសេចក្តីបំណងថា:

ព្រះពុទ្ធរូបនោះត្រូវរចនាដូច្នេះគឺ ទ្រង់គង់លើផ្កាឈូក ព្រះបាទទ្រង់ព្រះភ្នែន ព្រះហស្តស្តាំទ្រង់លើកឡើងស្មើនឹងព្រះអង្សា ( ស្មា ) ឯបាតព្រះហស្តបែរចេញក្រៅ ដើម្បីជូនពរសព្វសាធុការចំពោះសត្វលោកទូទៅ, នៅព្រះឧលាដ (ថ្ងាស) មានគំនូរជាសញ្ញានៃគតិបណ្ឌិត ព្រះភក្ត្រទ្រង់ញញឹមស្រស់ស្រាយ ។ បន្ទាប់ពីនេះ ព្រះសង្ឃនោះបាន

ពោលជាពាក្យសុភាសិតមួយ ដើម្បីឲ្យបុរសនោះស្តាប់ថា: «មនុស្សដែលមានគេនៈសម្បត្តិជាប់ទីជ័ខ្ទង់តែងមានគ្រោះថ្នាក់" តែអាត្មាអាជ័លោកនៅជិតនេះទើបអាត្មាពុំមានព្រួយបារម្ភ ។

ចំណែកបុរសនោះ កំនុនក្បាលសំដែងសេចក្តីគោរព, ប៉ុន្តែអាកប្បកិរិយារបស់បុរសនេះ មិនសមទៅតាមអធ្យាស្រ័យរបស់ព្រះសង្ឃនោះសោះ, កុងមួយរំពេច ស្រាប់តែបុរសនោះ ដើរឃ្លាតឆ្ងាយពីព្រះសង្ឃ មានចិត្តរំជួលយ៉ាងខ្លាំង ហើយដើរចុះ ទៀងជំហានវែងៗមុខជ្រួញខ្លាំង មានផ្នត់ជ្រួញពាក់កណ្តាលថ្ងាស ហើយគិតក្នុងចិត្តថា:

អញបានយកជីវិតទៅបូរទីជ័ទៅហ្វាយនាយ ច្រើនលើកច្រើនសាណាស់ហើយ សូម្បីតែជនមានកាយទុព្វលភាពក៏អញជួយដែរ តែអញមិនដែលមានប្រាក់សូម្បី ១ ភាគ ១០ នៃព្រះសង្ឃនេះសោះឡើយ, ឥឡូវអញកំពុងធ្លាក់ចុះក្នុងទុក្ខភ័យ លំបាកសែនលំបាក អញពាស់អាយុជិត ៤០ ឆ្នាំហើយ ។

តាមទំនៀមទម្លាប់នៃប្រទេសជប៉ុនថា: មនុស្សដែលមានអាយុ ៤០ ឆ្នាំ ឈ្មោះថា ចូលក្នុងវកភាព, គឺក្នុងវ័យនេះឯងដែលជនជាតិជប៉ុនត្រូវលះបង់ការងារគ្រប់យ៉ាង ដើម្បីស្វែងរកធម៌ ភាសាជប៉ុនហៅថា អ៊ិនគីយ៉ូ (Inkyo) ។

បុរសនោះថ្ងូរត្អូញត្អែជាខ្លាំង ហើយពោលចំពោះខ្លួនឯងថា អញ

គ្មានចៅហ្វាយនាយទេ អញមិនអាចមានភ័ព្វសំណាងរកចៅហ្វាយនាយថ្មីបានទៀតឡើយ, ប្រាក់ដែលព្រះសង្ឃនេះកាន់នៅព្រះហស្តលោក-មួយចំណែក អាចឲ្យគុណូបការៈជាយ៉ាងក្រៃលែង តែព្រះសង្ឃនេះមិនអាចឲ្យប្រាក់នេះមកអញទេ ៗ ក្នុងពេលនោះ សេចក្ដីលោភលន់នាំបណ្ដាលឲ្យឈាមក្នុងបេះដូងបុរសនោះកករល្អក់ជាខ្លាំង, ដូចកាលបុរសនោះចង់ឲ្យព្រះសង្ឃមានគ្រោះថ្នាក់ដល់អនិច្ចធម្ម ឬក្លួចទុកប្រាក់នេះនៅកន្លែងណាមួយ ខ្លួននឹងបានប្រាក់នោះ រត់ទៅទីឆ្ងាយបាត់ទៅ, ដូចកាលបុរសនោះ មានចិត្តបាបអកុសលចូលមកលុកលុយកាន់តែខ្លាំងឡើង ប្រាថ្នាចង់បានប្រាក់ភ្លាម ៗ ក៏គិតក្នុងចិត្តថា មិនជាអ្វីទេ!... ចិត្តរបស់មនុស្សតែងមានកុសល នឹងអកុសលផ្លាស់វេនគ្នាទៅវិញទៅមក យើងត្រូវតែឆ្លៀតឱកាសនេះ ដើម្បីកុំឲ្យចិត្តបាបកើតឡើងបាន ៗ

លោកតាដម៉ាស្ហុម ប្រឹងតស៊ូនឹងចិត្តបាបយ៉ាងអស់ទំហឹង, បន្តិចមកចិត្តបាបនេះ ទំសង្កត់លើចិត្តបុណ្យ បុរសនេះខំរកមធ្យោបាយដើម្បីនឹងលួចប្រាក់ព្រះសង្ឃនោះ មិនឲ្យលោកដឹង ឬចាប់ភ័ស្តុតាងបាន, តែបុរសនេះ, នៅតែសំដែងអាកប្បកិរិយាស្និទ្ធស្នាលចំពោះព្រះសង្ឃជានិច្ច ៗ

ឯព្រះសង្ឃមិនបានឃើញសេចក្ដីប្រែចិត្តនៃបុរសនោះសោះ លោកក៏មិនអាចមានសេចក្ដីសង្ស័យចំពោះបុរសនោះ ដែលទុកជាកល្យាណមិត្ត

របស់លោក ។

ឯព្រះសង្ឃនិងបុរសនោះក៏បានទៅដល់ទីក្រុងកុសាណា ។ នៅទីនោះ មានផែសមុទ្រមួយ ដែលត្រូវចូនទូកបើកក្ដោងទើបទៅដល់ត្រើយម្ខាង, ឯអ្នកបម្លងលុះរៀបចំមនុស្សបានចំនួន ៣០ នាក់ហើយ ក៏ចេញទូកទៅៗ

លុះព្រះសង្ឃនេះ ឡើងគង់លើទូកហើយ លោកក្ដាត់ព្រះបាទ ទៀបនឹងធ្លាក់ទៅក្នុងទឹក តែមិនមានគ្រោះថ្នាក់អ្វីទេ ។ ពេលនោះ បុរសក៏នឹកឃើញនូវមធ្យោបាយមួយ ដែលនឹងធ្វើឲ្យព្រះសង្ឃនោះធ្លាក់ ទៅក្នុងទឹក ។

ព្រះសង្ឃនិងបុរសនោះ បិតនៅកន្ទៃឆ្ងាយពីអ្នកឯទៀត កញ្ចប់ប្រាក់នៅកណ្ដាល ។ បុរសនោះបង្ហាញលោកសង្ឃនូវត្រីមួយមានពណ៌ ក្រហមកំពុងហែលទឹកជិតទូក ។ ឯព្រះសង្ឃក៏ឲនព្រះកេសមើល ត្រីក្នុងទឹក ។

ខណៈនោះ បុរសក៏ប្រានព្រះសង្ឃឲម្លាក់ទៅក្នុងទឹកទៅ ។ រួចហើយ រង់ចាំមួយស្របក់ ក៏ស្រែកយ៉ាងខ្លាំងថា សូមឈប់ទូកសិន ព្រះសង្ឃ ដែលនិមន្តមកជាមួយខ្ញុំលោកធ្លាក់ទៅក្នុងទឹកទៅហើយ ។

តែក្នុងពេលនោះមានរ៉ាយោបក់បោកមកខ្លាំងបំប៉ោងក្ដោងទូក, ធ្វើ ទូកនោះឲ្យអណ្ដែលលឿនទៅឆ្ងាយ, ព្រះសង្ឃនោះក៏លិចលង់កណ្ដាល សមុទ្រនោះទៅ ។ (នៅមានត)

# រឿងស្រីគ្រប់ល័ក្ខណ៍

(តមក)

លោក យុក-វធីរ រៀបរៀង លោក ផេង-ជ្រីវ ពិនិត្យ

---

សិរីវឌ្ឍន៍ញឹមៗ ហើយឆ្លើយទទួលដោយគោរពថា៖

– បាទ! សូមអរគុណច្រើន សំឡាញ់!

នៅថ្ងៃដែលស្វាមីភរិយាថ្មី សុំលាឪពុកម្ដាយចេញទៅនៅភូមិថ្មី ធនសេដ្ឋីឥតមានចែកទ្រព្យសម្បត្តិអ្វីឲ្យសោះ ។ ឪពុកសោភណាធ្វើដូច្នេះ មិនមែនស្អប់កូនស្រីខ្លួនទេ គឺដើម្បីផ្ចាញ់ផ្ចាលសំឡាញ់គាត់-តែប៉ុណ្ណោះ ។

សិរីវឌ្ឍន៍នឹងសោភណាទៅកាប់គាស់ដីធំដ៏រានព្រៃ ហើយសង់ខ្ទមមួយគ្រាន់ជាទីសំណាក់អាស្រ័យ ។ ឯប្រដាប់សម្រាប់គាស់រាននេះ នាងទៅសូមខ្ចីពីអ្នកស្រុកដែលនៅជិតខាង ។ ប៉ុន្តែនាងបានលាក់ប្រាក់កាសខ្លះជារបស់នាង ហើយម្ដាយក៏លួចឲ្យខ្លះយកទៅផង ដើម្បីទិញអង្ករបន្តពេលទម្រាំប្ដីប្រកបការងារបាន ។

រៀងរាល់ថ្ងៃ ប្ដីតែងទៅរកកាប់ឫស្ស ទុកឲ្យប្រពន្ធនៅមើលរក្សាខ្ទម ។ ដោយសោភណាជាស្ត្រីមិនចេះប្រកាន់ខ្លួនតាំងពីដើមមក នាងបោសសំអាតផ្ទះជានិច្ច ។ គ្រន់ដីនៅជិតខាងខ្ទមដែលប្ដីនាងបានកាប់គាស់យកកូនឈើចោលអស់ហើយនោះ នាងរៀបចំធ្វើជាកន្លែងដាំស្លឹក

ស្រែ ជាថ្នាលដាំជីរ ខ្ទឹម នឹងបន្លែផ្សេងៗមានត្រប់ ម្ទេស ស្ពៃជាដើម ដែលនាងទៅសុំពូជពីផ្ទះជិតខាងមក ។ អុសដែលប្តីកាប់បានមក នាងយកទៅហាលថ្ងៃ ។ កាលណាប្តីទៅស្រែ នាងនៅផ្ទះ ពូលអុសស្ងួតយកទៅលក់ ។ ក្នុងការចិញ្ចឹមជីវិត នាងមិនចេះអៀនខ្មាសទេ ឲ្យតែកិច្ចការនោះប្រកបដោយធម៌ហើយចំរើនផង ។ ប៉ុន្តែ លោកណា មានសេចក្តីអៀនខ្មាសបំផុត ចំពោះតែការទុច្ចរិត នឹងអំពើលោភ ។ ម៉្លោះហើយ ដោយការស្រុះចិត្តគំនិតគ្នា គូស្វាមីភរិយានោះបើមិនបានកេរ្តិ៍ពីពុកម៉ែឲ្យក៏ដោយ ក៏គង់អាចញ៉ាំងជីវភាពឲ្យប្រព្រឹត្តទៅបានស្រួល ត្រាន់តែមិនអាចធ្វើជាអ្នកមានទ្រព្យបានតែប៉ុណ្ណោះ ។ នាងតែងសង្ឃឹមទុកជានិច្ចថា ទេវតានឹងមិនមើលរំលងចំពោះមនុស្សសុចរិតឡើយ ។

ចាប់តាំងពីពេលដែលសិរីវឌ្ឍន៍នឹងលោកណា ទៅតាំងទីលំនៅទីនោះ អ្នកភូមិជិតខាងបានទទួលសេចក្តីសុខក្នុងការធ្វើដំណើរទៅមកត្រង់ភូមិចាស់នោះ ។ ទោះយប់ក្តី ថ្ងៃក្តី គេលែងដែលប្រទះខ្មោចលង ឬក៏ព្រាយប្រែក្រោកត្បូងដែលជាហេតុនាំឲ្យសេចក្តីតក់ស្លុត ។ ក្នុងរាត្រីកាល គេលែងក្រឡេកឃើញព្រាយហោះដូចមុនទៀតហើយ ។ ឥឡូវសូម្បីតែអាចម៍ផ្កាយធ្លាក់ ក៏គេមិនតាំងដែលឃើញផង ។

ដូច្នេះអ្នកភូមិទាំងឡាយមានសេចក្តីស្ញើចនឹងនឹកឆ្ងល់ថា គ្រួសារនេះប្រហែលជាមនុស្សវិជ្ជាអ្វីខ្លាំងពូកែណាស់ បានជាខ្មោចមិនហ៊ានធ្វើទុក្ខ ។

មិនតែប៉ុណ្ណោះ ការសរសើរអំពីសេចក្ដីសុខក្នុងគ្រួសារ ក៏មានស្ទើរតែគ្រប់មាត់ថែមទៀត គឺថាគេមិនដែលឮប្ដីប្រពន្ធមានពាក្យតូចពាក្យធំដាក់គ្នាដល់ម្ដងសោះ កុំនិយាយដល់ទៅការឈ្លោះប្រកែក ។ កាលណាឃើញនាងទូលទសលក់ គេតែងនាំគ្នាគណិត ព្រោះគេដឹងថានាងជាធីតានៃសេដ្ឋី ម្ដេចឡើយអក់ញ មកយកប្ដីក្រខ្សត់ដូច្នេះ ។ ចំណែកសោកណាវិញមានមុខស្រស់ជានិច្ច ព្រោះនាងយល់ថា: "សេចក្ដីសុខរបស់មនុស្សពុំមែននៅត្រង់មានទ្រព្យឬក្រខ្សត់ទេ គឺនៅត្រង់មានការធ្វើ ហើយនិងពេញចិត្តចំពោះវាសនារបស់អាត្មា" ។

នៅជំបន់នោះ មានមាណពម្នាក់ឈ្មោះ "រូបសិរី" ជាបុត្រនៃបុណ្ណសេដ្ឋី ។

រូបសិរីតែងតែទទួលនូវការថ្នាក់ថ្នមពីសំណាក់នៃមាតាបិតា ហើយពុំដែលធ្វើការហត្ថកម្ម មានការបោសសំអាតទីលំនៅជាដើមម្ដងសោះឡើយ ។ គេមានសិទ្ធិក្នុងការដើរលេងតាមអំពើចិត្ត បើមានប្រព្រឹត្តខុសឆ្គាំឆ្គងត្រង់បទណាមួយ មាតាបិតាតែងអធ្យាស្រ័យអត់ទោសឲ្យជាធម្មតា ។ ម្ល៉ោះហើយរូបសិរីមានចិត្តក្អេងក្អេន រហូតដល់ទៅហ៊ានប្រព្រឹត្តអបាយមុខគ្រប់យ៉ាង ហើយជាពិសេស នូវអំពើមាតុគ្រាម ។ អ្នកស្រុកទាំងឡាយដែលមានសីលធម៌ក្នុងខ្លួន មានសេចក្ដីធុញទ្រាន់ពន់ពេក នឹងការប្រព្រឹត្តមិនគប្បីនៃសេដ្ឋីបុត្រនេះ ។

ថ្ងៃមួយ សោភណាខ្ទូលៗសទៅលក់តាមផ្ទះអ្នកស្រុក ហើយបាន ទៅដល់លំនៅរបស់វីរកាល បើបានឃើញនាងកាលណា ស្រាប់តែមាន ចិត្តប្រតិព័ទ្ធយ៉ាងសាហាវស្ទើរទប់ពុំបាន ។ ក្រោយដែលនាងដើរហួស ទៅ សេដ្ឋីបុត្រជណ្ដឹងសួរអ្នកជិតខាងថា នាងដែលខ្ទូលៗសលក់នេះ ជាកូនអ្នកណា ឬជាប្រពន្ធឈ្មោះណា ? ហេតុអ្វីក្នុងពេលមុនក៏មិនដែល ឃើញ? ។ គេប្រាប់ថានាងជាសេដ្ឋីធីតាម្នាក់ដូចលោកដែរ ប៉ុន្តែមិនដឹង ហេតុម្ដេចបានជាមាតាបិតាដាក់ទុកឲ្យមកអ្នកក្រខ្សត់ដូច្នេះ ។ សព្វថ្ងៃ តាមការសង្កេតឃើញថា នាងមានការនឿយហត់នួយអាណិតពេក ។ រាល់ ថ្ងៃ តែកាលណាប្ដីចេញទៅព្រៃ ខ្លួនត្រូវតែខ្ទូលៗសដើរលក់ជានិច្ច ។

បសិរីទឹកថា នាងនេះជាកូនសេដ្ឋីដូចអញដែរ ។ ធម្មតាមនុស្ស រមែងតែពេញចិត្តចំពោះទ្រព្យសម្បត្តិ តែដែលនាងថ្វស់ថ្លោយធ្លាក់ខ្លួន មកជាស្រីកំសត់ ប្រហែលជាមានការណ៍សំខាន់អ្វីមួយជាអនិដ្ឋារម្មណ៍ ដែលយើងមិនអាចដឹងបាន ហើយដែលសេដ្ឋីធីតាធ្វើការសព្វថ្ងៃនេះ គឺពិតជាធ្វើតាំងចិត្ត ។ បើអញនិយាយបែចង់នាង ដោយប្រើមធ្យោ-បាយណាមួយខាងសន្តិវិធី នោះប្រាកដជានាងនឹងយល់ព្រមតាមមិនខាន បើការណ៍នេះបានសម្រេចដូចសេចក្ដីប្រាថ្នា ហើយ អញនឹងដំកល់នាង ជាភរិយាពេញទី អញមិនបោកបញ្ឆោតដូចស្ត្រីដែលអញបានគប ប្រសព្វក្នុងពេលមុនៗឡើយ អញមិនឲ្យនាងធ្វើការអ្វីទាំងអស់ គេទាសី

ប៉ប៉ូននាក់ឲ្យទៅបំរើនឹងធ្វើការជួស ជាក់ជួមប៉ត្រកឯបបោសអង្អែលមិនឲ្យនាងខ្វក់ចិត្តត្រង់បទណាសោះឡើយ ។

តាប់ពីថ្ងៃនោះមក រសជាតិឆ្ងាញ់នៃអាហារនឹងដំណេកលក់ស៊ប់ លះបង់រូបស៊ីរី ព្រោះភ្នែកគេកដុតពេលទូរទូនូសន្តាន ។ ចំណែកសោកណា ឥតដឹងខ្លួនបន្តិចសោះ ៖ គួរឲ្យអនិច្ចា នាងតែងតែសំដែងទឹកមុខញញឹម ជាធម្មតាចំពោះជននានាដែលនាងជួបប្រទះ ហើយនាងពុំដឹងថាចំពោះខ្លួននាង ទីងមានជនពាលសាមាន្យបំណងប្រព្រឹត្តអំពើអយុត្តធម៌ឡើយ ។

នៅភូមិនោះ មិនឆ្ងាយពីផ្ទះរូបស៊ីរីប៉ុន្មាន មានស្ត្រីម្នាក់ឈ្មោះ "យ៉ាស្មា" ។ នាងនេះជាអ្នកចេះតាយលក្ខណៈនឹងឫក្សជតាមនុស្ស ហើយមានស្ត្រីម្នាក់ទៀតឈ្មោះ «ម៉ាស្យា» ដែលតែងគេទទួលតានដោយអំពើលាមកម្យ៉ាង ហៅថា «ធ្វើមេអណ្តើក» ។

ដើម្បីញុាំងបំណងស្នេហាគ្នាឲ្យសម្រេចតាប់ ហើយដោយសទ្ធិវិធីផងនោះ រូបស៊ីរីក៏ចូលទៅគិតការណ៍ យ៉ាងស្ងាត់ជាមួយស្ត្រីពាំងពីរនាងលើ ។ ដើម្បីឲ្យគេយកចិត្តទុកដាក់ដ៏មិនតចំពោះរឿងខ្លួន សេដ្ឋីបុត្រត្រូវលួចប្រាក់អាពុក ចំនួនពីររយកហាបណៈយកទៅឲ្យមួយរយម្នាក់ ហើយនិយាយដោយទឹកមុខក្រៀមក្រំនឹងស្ត្រីទាំងពីរថា:

- សូមលោកមីងមេត្តាករុណាតកូន សព្វថ្ងៃនេះស្ទើររលេះរលួយដើមប្រមាត់អស់ហើយ ព្រោះតែបង់បានរូបនាងនោះមកផ្តេកផ្តិត ធ្វើជាពនិតា

លោកម៉ឺនដែលចេះកលល្បិចមានមាយាយ៉ាងណាខ្លះ សូមយកមកប្រើឲ្យបានក្នុងពេលនេះណា លោកម៉ឺន !

ម៉ឺនយ៉ាំស្លា មុនដំបូងនៅស្ងៀម ធ្វើទឹកមុខជាអ្នកមញ្ចឹត រួចទើបឆ្លើយដោយសំដីមួយៗថា:

-កុំព្រួយកង្វល់ៗមកពីនឹមម៉ឺនម្ចាស់ ម៉ឺននឹងខំប្រឹងជួយដោយពេញសមត្ថភាព សូមក្ជួយទុកចិត្តចុះ ។

បន្ទាប់ពីនោះមក រូបសិរីទៅនិយាយនឹងម៉ឺនម៉ាំស្បាទៀត ។ អ្នកអង្គស្រីនេះសុំឲ្យជួយថ្នាក់ថ្នមលួងលោម នឹងពន្យល់សោកនាដោយប្រការយ៉ាងណា ដើម្បីឲ្យនាងឃ្លាតនឹងបែកចិត្តចេញពីប្តី ហើយឲ្យបាក់ចិត្តមកលើខ្លួន ប្រសិនបើការណ៍នេះបានសម្រេចហើយ ម៉ឺនម៉ាំស្បានឹងត្រូវទទួលរង្វាន់ថែមទៀត ។ ប៉ុន្តែសេដ្ឋីបុត្រប្រាប់ថែមទៀតថា មុននឹងពាក់ការនេះ សូមលោកម៉ឺនអញ្ជើញទៅប្រឹក្សាជាមួយម៉ឺនយ៉ាំស្លាផង ដើម្បីកុំឲ្យខ្វែងយោបល់គ្នា ព្រោះខ្ញុំបានបានពឹងគាត់ឲ្យជួយក្នុងរឿងនេះដែរ ។

ថ្ងៃក្រោយមក គេឃើញម៉ឺនម៉ាំស្បា ទៅឯផ្ទះម៉ឺនយ៉ាំស្លាដើម្បីពិភាក្សាគ្នា ។

ម៉ឺនម៉ាំស្បាសួរទាំងទឹកមុខញញឹមញញែមចំពោះម៉ឺនយ៉ាំស្លាថា :

-ដូចម្តេចទៅអ្នកបង ឮថារូបសិរីជាកូនបុណ្យសេដ្ឋីបានសុំឲ្យជួយគិតការអ្វី ?

មីងយ៉ាស្នាយកដៃទៅបិទមាត់មីងម៉ាស្សាហើយប្រាប់ថា:

-កុំនិយាយឮពេក ! ចុះដូចម្ដេចក៏អូនដឹងរឿងនេះ ? ការណ៍នេះមានទោស ត្រូវប្រយ័ត្ន !

មីងម៉ាស្សាយកដៃទាំងពីរខ្ទប់មាត់សើច ហើយឆ្លើយតិច ៗ ថា:

-គេបានទៅពឹងឲ្យខ្ញុំជួយដែរ ហើយបង្គាប់ខ្ញុំឲ្យមកជួបមីងអ្នកបងមុននឹងធ្វើការ ៗ ម្យ៉ាងទៀត គេឲ្យអ្នកបងប៉ុន្មាន ?

-មួយរយកហាបណៈ, ចុះអូនឯង គេឲ្យប៉ុន្មានដែរ ?

-មួយរយដូចគ្នា ៗ

មីងម៉ាស្សាពោលថែមទៀតថា:

-អ្នកក្រឡត់ថែបនេះ ឥតពីបាកអ្វីទេអ្នកបង លុយនេះស៊ីឆ្ងាញ់ណាស់ ៗ អម្បាលពេលមុនៗ សុទ្ធតែប្រពន្ធអ្នកមានយសសក្តិ នឹងកូនអ្នកមានសម្បត្តិធន ម៉េចគង់ខ្ញុំគិតការកើត ឥតមានផលរមាស់អ្វី ដូចជាប្រពន្ធលោក «សាយ៉ា» ទៅខូចជាមួយអ្នកកំលោះមិនគិតស្នាដៃខ្ញុំ ! កូនក្រមុំលោក "ចុគ្គលី" ទៅស្រឡាញ់ "អាម៉ូវតូវ" ហើយបានជាប់គ្នាជាប្តីប្រពន្ធរហូតដល់សព្វថ្ងៃ មិនគិតស្នាដៃខ្ញុំ អ្នកបងឃើញឬទេ សុទ្ធតែអ្នកមានលុយ ៗ

មីងយ៉ាស្នានិយាយកាត់ថា:

-បំណាច់ទទួលលុយគេហើយ យើងត្រូវធ្វើការម៉ត់ចត់ឲ្យគេ មែន

ឬទេអូន ? ដូច្នេះអូនឯងនឹងនៅចាំបងធ្វើការមុនសិន ។

ព្រឹកស្អែកប្រហែលម៉ោងប្រាំបី លោកគណាតែងតែខ្ចូលខ្សែទៅលក់ជាធម្មតា ។ លុះមកដល់ផ្ទះម៉ឹងយ៉ាំស្នា ។ ស្រែកហៅនាងឲ្យចូលដើម្បីទិញខ្សែ ។ គាត់សំដៅផងទឹកមុខរីករាយនឹងពក់ទាក់ចំពោះនាងប្លែកពីធម្មតា ។ ក្រោយដែលបានទិញខ្សែរួចហើយ គាត់ធ្វើជាចាប់ដៃអង្អែលស្នាតាង ព្រមទាំងសរសើរចំពោះសាច់ឈាមទំនទឹកមុខប្រិមប្រិយដោយសំដីទន់ផ្អែម រួចនិយាយសុំទោសថា:

–នែកូន! ម្ដាយសុំទោស សូមស្ដាប្បន្តិច!

លោកគណាដំកបទៅវិញដោយពំពាសុភាពថា:

–ចា៎ះ! លោកម៉ឹង! មានការណ៍អ្វី អញ្ជើញសួរចុះ ឥតមានទោសទេ លោកម៉ឹងក៏ដូចជាម្ដាយខ្ញុំដែរ ។

–ម្ដាយឃើញកូនមានរូបល្អ មើលទៅទឹកមុខក៏ស្រស់ សាច់ឈាមក៏ស្អាត សមជាអ្នកស្រណុក ម្ដេចឡើយទៅជាក្រ ខ្ចូលខ្សែលក់យ៉ាំងនេះ ម្ដាយចង់សុំពិនិត្យលក្ខណៈបន្តិច តាមវិជ្ជាហោរដែលម្ដាយបានរៀនខ្លះនោះ ។

ចំណុចនេះត្រូវនឹងបំណងលោកគណាដែរ ទើបនាងហុចដៃឲ្យម៉ឹងយ៉ាំស្នាពិនិត្យ ។ លុះពិនិត្យដៃទាំងពីរសព្វគ្រប់ហើយ ម៉ឹងយ៉ាំស្នានិយាយដោយសំដីម៉ឺងម៉ាត់ថា :

-កូនឯង បើតាមលក្ខណៈនិងឫក្សជាតិជាអ្នកមានសម្បត្តិស្តុក
ហើយឥតនឿយលំបាកឡើយ ប៉ុន្តែត្រង់បាតដៃស្តាំ ទាស់ខាងខ្សែរ
មកបាំងបន្តិច តែទោះជាដូច្នេះក៏ដោយ ព្រះចន្ទនឹងរបូតពីកហូមិន
មិនឆាប់ ។

ឮដូច្នោះ សោភណាទឹកអស្រងូច ដោយយល់ថាថ្ងៃណាមួយ
ព្រមទាំងប្តីជាទីស្នេហាមុខជានឹងបានរំដោះពីការក្រលំបាកជាមិនខាន :

មីងយ៉ាំស្មាប្រាប់បញ្ជាក់ថា :

-ខ្ញុំនាយប៉ុន្មានមាត់នេះ មានការបកស្រាយវែងបន្តិច តែត្រង់
ប្រញាប់ទៅលក់ខស ចូរទៅលក់ចុះ ។

ដោយចង់ដឹងរឿងឲ្យបានច្បាស់លាស់ សោភណាក៏អង្វរមីងយ៉ាំ
សុំបកស្រាយឲ្យស្តាប់ ។

គាត់ចាប់ទាញម្តងទៀត នូវដៃទាំងគូនៃសោភណា មកដាក់
នៅលើភ្លៅគាត់ធ្វើជាសំឡឹងពិនិត្យដោយស្ងៀមស្ងាត់ រួចទើបនិយាយ

-ដែលម្តាយថា មានខ្សែរាហ៊ុបាំងបន្តិចនោះ រាហ៊ុជាសត្រូវ
លោកខែ រមែងតែរកចាប់ព្រះចន្ទលេប ប៉ុន្តែលេបមិនយូរទេ
ព្រះចន្ទនឹងរបូតពីកណ្ដាប់ដៃ ដោយសារកម្លាំងបុណ្យ គឺជាកូនសត្វ
ឋិតនៅក្នុងកណ្ដាប់ដៃរាហូ បានជាកូនមានសេចក្តីនឿយហត់ដូច្នេះ
តាមខ្ញុំនាយ បើម្តាយថាហើយ សូមកូនកុំអាក់អន់ចិត្ត...